# យុទ្ធសាស្ត្រអ៊ីនឈាន់
# "ធ្វើឲ្យសិទ្ធិក្លាយជាការពិត"
# សម្រាប់ជនពិការ
# ប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក

UNITED NATIONS
ESCAP
Economic and Social Commission for Asian and the Pacific

**ការបោះពុម្ពផ្សាយរបស់អង្គការសហប្រជាជាតិ**
**រក្សាសិទ្ធិដោយ អង្គការសហប្រជាជាតិ ឆ្នាំ២០១២**
**រក្សាសិទ្ធិគ្រប់យ៉ាង**
**បោះពុម្ពនៅទីក្រុងបាងកក**
**ST/ESCAP/2648**

**បំរាម**
ការផលិតឡើងវិញនូវខ្លឹមសារដែលមាននៅក្នុងសៀវភៅបោះពុម្ពផ្សាយនេះ សម្រាប់លក់ឬគោលបំណងពាណិជ្ជកម្មផ្សេងទៀត រួមទាំងការប្រកាសផ្សាយជាសាធារណៈ និងផ្សាយពាណិជ្ជកម្ម ត្រូវបានហាមឃាត់ ក្នុងករណីដែលគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរពីម្ចាស់កម្មសិទ្ធិ។ ពាក្យសុំការអនុញ្ញាត ត្រូវដាក់ជូនទៅនាយកផ្នែកអភិវឌ្ឍសង្គមនៃ គណៈកម្មាធិការអង្គការសហប្រជាជាតិផ្នែកសេដ្ឋកិច្ច សង្គម ប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក តាមអាសយដ្ឋានអ៊ីម៉ែល escap-sdd@un.org ដោយភ្ជាប់ជាមួយនូវសេចក្ដីថ្លែងពីគោលបំណង និងទំហំនៃការផលិតឡើងវិញនោះ។

**អង្គការសហប្រជាជាតិ**
គណៈកម្មាធិការអង្គការសហប្រជាជាតិផ្នែកសេដ្ឋកិច្ច សង្គម ប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក
បាងកក ខែវិច្ឆិកា ឆ្នាំ២០១២

# មានជនពិការ

# ៦៥០

# លាននាក់

## រស់នៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក

**យើងដាក់ចេញនូវទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក ថ្មីឆ្នាំ២០១៣- ២០២២ ចូរយើងផ្តោតទៅលើការដោះស្រាយបញ្ហាដែលនៅសេសសល់។ តាមរយៈការអនុម័ត និងការអនុវត្តយុទ្ធសាស្ត្រអ៊ីនឈាន់ លោកអ្នកអាចធានាជួយដាក់បញ្ចូលពិការភាពទៅក្នុងរបៀបវារៈអភិវឌ្ឍន៍ក្រោយឆ្នាំ២០១៥ ។**

**បាន គីមូន**
**អគ្គលេខាធិការ**
អង្គការសហប្រជាជាតិ



# សេចក្តីពន្យល់អំពី អេស្កាប់

គណៈកម្មាធិការអង្គការសហប្រជាជាតិផ្នែកសេដ្ឋកិច្ចនិងសង្គមប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក (អេស្កាប់) គឺជាផ្នែកមួយនៃភ្នាក់ងារអភិវឌ្ឍក្នុងតំបន់របស់អង្គការសហប្រជាជាតិ ដែលបម្រើជាមជ្ឈមណ្ឌលអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមដ៏សំខាន់របស់អង្គការសហប្រជាជាតិ ប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក។ អេស្កាប់ មានអាណត្តិក្នុងការជំរុញកិច្ចសហប្រតិបត្តិការរវាងសមាជិកទាំង៥៣ និងសមាជិកធម្មតាទាំង៩របស់ខ្លួន។ អេស្កាប់ ផ្តល់នូវការតភ្ជាប់ជាយុទ្ធសាស្ត្រថ្នាក់តំបន់រវាងបណ្តាកម្មវិធីនិងបញ្ហាក្នុងកម្រិតប្រទេស និងពិភពលោក។ អេស្កាប់ ជួយគាំទ្រដល់បណ្តារដ្ឋាភិបាលក្នុងតំបន់ ក្នុងការពង្រឹងជំហរថ្នាក់តំបន់ និងតស៊ូមតិលើវិធីសាស្ត្រថ្នាក់តំបន់ ឱ្យមានដំណោះស្រាយត្រូវទៅនឹងការប្រឈមផ្នែកសង្គម សេដ្ឋកិច្ច របស់តំបន់អាស៊ីនិងប៉ាស៊ីហ្វិក នៅក្នុងពិភពលោកមួយដែលកំពុងធ្វើសាកលភាវូបនីយកម្ម។ លេខាធិការដ្ឋានរបស់ អេស្កាប់ មានទីតាំងឋិតនៅទីក្រុងបាងកក។ សម្រាប់ព័ត៌មានបន្ថែម សូមចូលមើលគេហទំព័ររបស់យើងនៅអាសយដ្ឋាន www.unescap.org ។

# សមាជិក និងសមាជិកធម្មតារបស់ អេស្កាប់

## សមាជិក

អាហ្វហ្គានីស្ថង់
អារម៉ានី
អូស្ត្រាលី
អាហ្សែរបៃហ្សង់
បង់ក្លាដែស
ប៊ូតង់
ប្រ៊ុយណេ ដារុសសាឡឹម
កម្ពុជា
ចិន
សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ
ហ្វីជី
បារាំង
ហ្សកហ្ស៊ី
ឥណ្ឌា
ឥណ្ឌូនេស៊ី
អ៊ីរ៉ង់ (សាធារណរដ្ឋអ៊ីស្លាម)
ជប៉ុន
កាហ្សាស្ថាន
គីរីបាទី
គីរហ្ស៊ីស្ថាន
សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ
ម៉ាឡេស៊ី
ម៉ាល់ឌីវ
ម៉ារសាលអាយលែន
មីក្រូនេស៊ី (រដ្ឋសហព័ន្ធ)
ម៉ុងហ្គោលី
ភូមា
ណូរូ
នេប៉ាល់
ហូឡង់
នូវែលហ្សេឡង់
ប៉ាគីស្ថាន
ប៉ាឡូ
ប៉ាពូ ញូ ហ្គីនេ
ហ្វីលីពីន
សាធារណរដ្ឋកូរ៉េ
សហព័ន្ធរុស្ស៊ី
សាម៉ូអា
សឹង្ហបុរី
សូឡូម៉ុន អាយលែន
ស្រីលង្កា
តាហ្ស៊ីគីស្ថាន
ថៃ
ទីម័រខាងកើត
តុងហ្គា
ទួរគី
ទួរមេនីស្ថាន
ទូវ៉ាលូ
ចក្រភពអង់គ្លេស និង អៀរឡង់ខាងជើង
សហរដ្ឋអាមេរិក
អ៊ុយបេគីស្ថាន
វ៉ានូអាទូ
វៀតណាម

## សមាជិកធម្មតា

អាមេរិកាំង សាម៉ូអា
ឃុក អាយលែន
ប៉ូលីនេស៊ីបារាំង
ហ្គាម
ហុងកុង ចិន
ម៉ាកាវ ចិន
ញូវ កាឡេដូនី
នីយូ
ម៉ារីយ៉ាណាអាយលែនខាងជើង

# មាតិកា


សេចក្តីផ្តើម ២

សេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីស្តីពីទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក២០១៣-២០២២ ៣

យុទ្ធសាស្ត្រអ៊ីនឈាន់ "ធ្វើឱ្យសិទ្ធិក្លាយជាការពិត" សម្រាប់ជនពិការប្រចាំតំបន់ អាស៊ីនិងប៉ាស៊ីហ្វិក ១២

ក. សារតារ ១២

ខ. ការណែនាំអំពីគោលការណ៍និងគោលនយោបាយគន្លឹះ ១៣

គ. គោលដៅនិងទិសដៅអ៊ីនឈាន់ ១៥

ឃ.គម្រូសម្រាប់ការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព៖ ថ្នាក់ជាតិ ថ្នាក់អនុតំបន់ និងថ្នាក់តំបន់ ២៨

១.ថ្នាក់ជាតិ ២៨

២.ថ្នាក់អនុតំបន់ ២៩

៣.ថ្នាក់តំបន់ ២៩

ឧបសម្ព័ន្ធ

លក្ខខណ្ឌប្រតិបត្តិរបស់ក្រុមការងារស្តីពីទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ៣១

# សេចក្តីផ្តើម

បណ្តារដ្ឋាភិបាលនៃតំបន់ អាស៊ីប៉ាស៊ីហ្វិក បានជួបប្រជុំគ្នានៅក្នុងទីក្រុងអ៊ីនឈាន់ សាធារណរដ្ឋកូរ៉េ ពីថ្ងៃទី២៩ ខែតុលា ដល់ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១២ ដើម្បីរៀបចំអភិវឌ្ឍទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីប៉ាស៊ីហ្វិកថ្មី សម្រាប់រយៈពេលពីឆ្នាំ ២០១៣ ដល់ឆ្នាំ២០២២។ មានតំណាងរបស់បណ្តាអង្គការសង្គមស៊ីវិលជាច្រើនក៏បានចូលរួមដែលរួមមានទាំងអង្គការជនពិការ និងអង្គការសម្រាប់ជនពិការ ហើយក៏មានការចូលរួមពីបណ្តាអង្គការអន្តររដ្ឋាភិបាល ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍជាច្រើន និងប្រព័ន្ធអង្គការសហប្រជាជាតិផងដែរ។

កិច្ចប្រជុំអន្តររដ្ឋាភិបាលកម្រិតខ្ពស់ ស្តីអំពីការពិនិត្យមើលឡើងវិញចុងក្រោយនៃការអនុវត្តន៍ ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក២០០៣-២០១២ ត្រូវបានរៀបចំដោយគណៈកម្មាធិការអង្គការសហប្រជាជាតិផ្នែកសេដ្ឋកិច្ចនិងសង្គមប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក (ESCAP) និងត្រូវបានទទួលធ្វើជាម្ចាស់ផ្ទះដោយរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ។ កិច្ចប្រជុំនេះ បានធ្វើសេចក្តីសន្និដ្ឋានលើទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិកលើកទីពីរ ឆ្នាំ២០០៣-២០១២ និងបានដាក់ចេញនូវទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិកថ្មី។

បណ្តារដ្ឋាភិបាលនៅក្នុងកិច្ចប្រជុំអន្តររដ្ឋាភិបាលកម្រិតខ្ពស់បានអនុម័តសេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីស្តីពីទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ឆ្នាំ២០១៣-២០២២ និងយុទ្ធសាស្ត្រអ៊ីនឈាន់ "ធ្វើឱ្យសិទ្ធិក្លាយជាការពិត" សម្រាប់ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក។

យុទ្ធសាស្ត្រអ៊ីនឈាន់ ផ្តល់ឱ្យតំបន់អាស៊ីនិងប៉ាស៊ីហ្វិកនិងពិភពលោកនូវសំណុំឯកសារលើកដំបូងដែលមានការព្រមព្រៀងថ្នាក់តំបន់ក្នុងការដាក់បញ្ចូលពិការភាពទៅក្នុងគោលដៅអភិវឌ្ឍ។

ទសវត្សរ៍បានកសាងតាមរយៈការពិគ្រោះយោបល់យ៉ាងម៉ត់ចត់ជាមួយបណ្តារដ្ឋាភិបាល និងដៃគូពាក់ព័ន្ធនៃសង្គមស៊ីវិលអស់រយៈពេលជាងពីរឆ្នាំ។ យុទ្ធសាស្ត្រអ៊ីនឈាន់នេះរួមមាន ១០គោលដៅ ២៧ទិសដៅ និង ៦២សូចនាករ។

យុទ្ធសាស្ត្រអ៊ីនឈាន់កសាងបន្ថែមលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងក្របខណ្ឌសហសវត្សរ៍បីវ៉ាកូសម្រាប់សកម្មភាព និងបីវ៉ាកូបូកប្រាំឆ្ពោះទៅរកការដាក់បញ្ចូល គ្មានឧបសគ្គរារាំង និងសង្គមមួយដែលឈរលើសិទ្ធិជាមូលដ្ឋាន សម្រាប់ជនពិការនៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក។

យុទ្ធសាស្ត្រអ៊ីនឈាន់ នឹងធ្វើឱ្យតំបន់អាស៊ីនិងប៉ាស៊ីហ្វិកអាចកត់ត្រាតាមដានភាពរីកចំរើនឆ្ពោះទៅរកការកែលម្អគុណភាពនៃជីវិតនិងការអនុវត្តសិទ្ធិរបស់ជនពិការ៦៥០លាននាក់ នៅក្នុងតំបន់នេះដែលភាគច្រើនក្នុងចំណោមពួកគេកំពុងរស់នៅក្នុងភាពក្រីក្រ។ លេខាធិការដ្ឋានអេស្កាប់ត្រូវបានកំណត់ឱ្យធ្វើរបាយការណ៍អំពីភាពរីកចំរើននៅក្នុងការអនុវត្តសេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីនិងយុទ្ធសាស្ត្រអ៊ីនឈាន់ នៅរៀងរាល់បីឆ្នាំម្តងរហូតដល់ចុងទសវត្សរ៍គឺឆ្នាំ២០២២។

# សេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីស្តីពីទសវត្សរ៍ជនពិការ ប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ២០១៣-២០២២

*យើងខ្ញុំជារដ្ឋមន្ត្រីនិងតំណាងសមាជិកនិងសមាជិកចម្ងតានៃគណៈកម្មាធិការអង្គការសហប្រជាជាតិផ្នែកសេដ្ឋកិច្ចនិងសង្គមប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក (ESCAP) បានជួបប្រជុំគ្នានៅក្នុង **កិច្ចប្រជុំអន្តររដ្ឋាភិបាលកម្រិតខ្ពស់ស្តីពីការពិនិត្យមើលឡើងវិញចុងក្រោយនៃការអនុវត្តទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ឆ្នាំ២០០៣-២០១២** ដែលត្រូវបានរៀបចំឡើងនៅទីក្រុងអ៊ីនឈាន់សាធារណរដ្ឋកូរ៉េ ពីថ្ងៃទី២៩ ខែតុលា ដល់ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១២។*

*ដោយរំឮកឡើងវិញ* នូវសេចក្តីសម្រេចលេខ៣៧/៥២ របស់អង្គមហាសន្និបាតចុះនៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ១៩៨២ ដែលក្នុងនោះអង្គមហាសន្និបាតបានអនុម័តសកម្មភាពរបស់កម្មវិធីពិភពលោកទាក់ទងនឹងជនពិការ[១] និងសេចក្តីសម្រេចលេខ៤៨/៩៦ ចុះនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ដែលក្នុងនោះ អង្គមហាសន្និបាតបានអនុម័តវិធានបទដ្ឋានស្តីពីសមភាពនៃឱកាសសម្រាប់ជនពិការ ដែលក្នុងនោះជនពិការត្រូវបានទទួលស្គាល់ជាភ្នាក់ងារអភិវឌ្ឍផង និងជាអ្នកទទួលផលផង នៅក្នុងគ្រប់ទិដ្ឋភាពនៃការអភិវឌ្ឍ។

*ដោយរំឮកឡើងវិញផងដែរ* នូវសេចក្តីសម្រេចលេខ៦១/១០៦ របស់អង្គមហាសន្និបាតចុះ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៦ ដែលក្នុងនោះ អង្គមហាសន្និបាតបានអនុម័តអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងពិធីសារបន្ថែមរបស់អនុសញ្ញានេះដែលបានចូលជាធរមាននៅថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០០៨។

*ដោយរំឮកឡើងវិញជាបន្ថែម* នូវសេចក្តីសម្រេចលេខ៦៥/l របស់អង្គមហាសន្និបាតចុះនៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០ ដែលមានចំណងជើងថា "ការរក្សាសន្យារួមគ្នាសម្រេចគោលដៅអភិវឌ្ឍសហសវត្សរ៍" ដែលក្នុងនោះអង្គមហាសន្និបាតបានទទួលស្គាល់នៅក្នុងចំណោមគោលដៅផ្សេងៗទៀតថា គោលនយោបាយ និងសកម្មភាពត្រូវតែផ្តោតលើអ្នកក្រ និងអ្នកដែលរស់នៅក្នុងស្ថានភាពងាយរងគ្រោះបំផុត ដែលរាប់បញ្ចូលទាំងជនពិការ ដើម្បីឲ្យពួកគេទទួលបានផលប្រយោជន៍ពីភាពរីកចំរើនឆ្ពោះទៅរកការសម្រេចគោលដៅអភិវឌ្ឍសហសវត្សរ៍។

*ដោយស្វាគមន៍* ការសម្រេចរបស់អង្គមហាសន្និបាតក្នុងការរៀបចំកិច្ចប្រជុំថ្នាក់ខ្ពស់ស្តីពីការធ្វើឲ្យសម្រេចនូវគោលដៅអភិវឌ្ឍ សហសវត្សរ៍ និងគោលដៅអភិវឌ្ឍដែលបានព្រមព្រៀងគ្នាជាអន្តរជាតិផ្សេងៗទៀតសម្រាប់ជនពិការនៅកម្រិតប្រមុខរដ្ឋ និងរដ្ឋាភិបាល នៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣ ជាមួយប្រធានបទសំខាន់បំផុត "ទិសដៅបន្ទះ៖ របៀបវារៈអភិវឌ្ឍដែលមានការដាក់បញ្ចូលពិការភាពឆ្ពោះទៅរកឆ្នាំ២០១៥ និងបន្ទាប់ពីឆ្នាំ២០១៥"។[២]

*ដោយរំឮកឡើងវិញ* នូវសេចក្តីសម្រេចរបស់អង្គការសហប្រជាជាតិលេខ៦៦/២៩០ ចុះនៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១២ ចែងអំពីការយល់ជារួមមួយដែលត្រូវបានព្រមព្រៀងស្តីអំពីសន្តិសុខមនុស្ស និងចែងក្នុងចំណោមចំណុចផ្សេងទៀតថា បុគ្គលគ្រប់រូបជាពិសេសអ្នកដែលងាយរងគ្រោះមានសិទ្ធិមានសេរីភាពរួចផុតពីការភ័យខ្លាច និងមានសេរីភាពរួចផុតពីការខ្វះខាតដោយមានឱកាសស្មើៗគ្នាក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួន និងក្នុងការអភិវឌ្ឍន៍សក្តានុពលដែលខ្លួនមាន។

---

[១] A/37/351/Add.1 និង Corr.1, ឧបសម្ព័ន្ធ, ផ្នែក VIII, អនុសាសន៍ 1 (IV).

[២] មើលសេចក្តីសម្រេចរបស់អង្គមហាសន្និបាតលេខ ៦៦/១២៤ ចុះនៅថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០១១

*ដោយរំឭកឡើងវិញផងដែរ* នូវសេចក្តីសម្រេចលេខ៤៨/៣ របស់គណៈកម្មាធិការចុះនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ១៩៩២ ស្តីពីទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ឆ្នាំ១៩៩៣-២០០២ ដែលក្នុងនោះគណៈកម្មាធិការបានប្រកាសទសវត្សរ៍ថ្នាក់តំបន់ទីមួយនេះ នៅក្នុងពិភពលោក។

*ដោយរំឭកឡើងវិញជាបន្ថែម* នូវសេចក្តីសម្រេចលេខ៥៨/៤របស់គណៈកម្មាធិការ ចុះនៅថ្ងៃទី២២ ខែ ឧសភា ឆ្នាំ២០០២ ស្តីពីការលើកកម្ពស់ការដាក់បញ្ចូល គ្មានឧបសគ្គរាំង និងសង្គមមួយដែលឈរលើសិទ្ធិជាមូលដ្ឋាន សម្រាប់ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក នៅក្នុងសតវត្សរ៍ទីម្ភៃមួយដែលក្នុងនោះ គណៈកម្មាធិការបានប្រកាសពីការបន្តទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិកទៅទសវត្សរ៍ មួយទៀតគឺ២០០៣-២០១២។

*ដោយរំឭកឡើងវិញ* នូវសេចក្តីសម្រេចលេខ៥៩/៣ របស់គណៈកម្មាធិការ ចុះនៅថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការអនុវត្តន៍ថ្នាក់តំបន់នៃក្របខណ្ឌសហសវត្សរ៍ប៊ីវ៉ាកូសម្រាប់សកម្មភាព និងប៊ីវ៉ាកូបូកប្រាំឆ្ពោះទៅរកការដាក់បញ្ចូល គ្មានឧបសគ្គរាំង និងសង្គមមួយដែលឈរលើសិទ្ធិជាមូលដ្ឋាន សម្រាប់ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក នៅក្នុងអំឡុងទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក២០០៣-២០១២ ដែលក្នុងនោះ ក្នុងចំណោមសំណើផ្សេងៗទៀត គណៈកម្មាធិការបានស្នើសុំឲ្យសមាជិកនិងសមាជិកធម្មតាជួយគាំទ្រការអនុវត្តន៍ក្របខណ្ឌសហសវត្សរ៍ប៊ីវ៉ាកូសម្រាប់សកម្មភាព។

*ដោយរំឭកឡើងវិញផងដែរ* នូវសេចក្តីសម្រេចលេខ៦៤/៨ របស់គណៈកម្មាធិការ ចុះនៅថ្ងៃទី៣០ខែមេសា ឆ្នាំ២០០៨ ស្តីពីការអនុត្តន៍ថ្នាក់តំបន់នូវក្របខណ្ឌសហសវត្សរ៍ប៊ីវ៉ាកូសម្រាប់សកម្មភាព និងប៊ីវ៉ាកូបូកប្រាំឆ្ពោះទៅរកការដាក់បញ្ចូល គ្មានឧបសគ្គរាំង និងសង្គមមួយដែលឈរលើសិទ្ធិជាមូលដ្ឋានសម្រាប់ជនពិការនៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ដែលក្នុងនោះគណៈកម្មាធិការបានណែនាំឲ្យមានការប្រជុំអន្តររដ្ឋាភិបាលកម្រិតខ្ពស់មួយ ដើម្បីពិនិត្យមើលឡើងវិញនូវការអនុវត្តក្របខណ្ឌសហសវត្សរ៍ប៊ីវ៉ាកូសម្រាប់សកម្មភាព និងប៊ីវ៉ាកូបូកប្រាំនៅក្នុងឆ្នាំ២០១២ ដែលជាឆ្នាំធ្វើការសន្និដ្ឋានវាយតម្លៃអំពីទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក២០០៣–២០១២។

*ដោយរំឭកឡើងវិញជាបន្ថែម* នូវសេចក្តីសម្រេចលេខ៦៦/១១ របស់គណៈកម្មាធិការ ចុះនៅថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១០ ស្តីពីការរៀបចំថ្នាក់តំបន់សម្រាប់កិច្ចប្រជុំអន្តររដ្ឋាភិបាលកម្រិតខ្ពស់ស្តីពីការអនុវត្តន៍ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក២០០៣-២០១២ ដែលក្នុងនោះគណៈកម្មាធិការបានលើកទឹកចិត្តឲ្យមានការចូលរួមពីភាគីពាក់ព័ន្ធសំខាន់ៗទាំងអស់ នៅក្នុងដំណើរការត្រៀមរៀបចំឆ្ពោះទៅរកកិច្ចប្រជុំអន្តររដ្ឋាភិបាលកម្រិតខ្ពស់ដែលក្នុងចំណោមភាគីពាក់ព័ន្ធសំខាន់ៗទាំងនោះរួមមានទាំងអង្គការជនពិការនានាដែលមកពីតំបន់អាស៊ីនិងប៉ាស៊ីហ្វិកផងដែរ។

*ដោយរំឭកឡើងវិញ* នូវសេចក្តីសម្រេចលេខ៦៨/៧ របស់គណៈកម្មាធិការ ចុះនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១២ បានប្រកាសទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក២០១៣-២០២២ និងបានជំរុញសមាជិកនិងសមាជិកធម្មតាទាំងអស់ឲ្យចូលរួមដោយសកម្មក្នុងកិច្ចប្រជុំអន្តររដ្ឋាភិបាលកម្រិតខ្ពស់ហើយឲ្យធ្វើការពិចារណា និងអនុម័តក្របខណ្ឌយុទ្ធសាស្ត្រមួយដើម្បីដឹកនាំការអនុវត្តន៍ទសវត្សរ៍ដែលផ្អែកលើគោលការណ៍ និងកាតព្វកិច្ចទូទៅដូចមានចែងនៅក្នុងអនុសញ្ញា ស្តីពីសិទ្ធិជនពិការ។

*ដោយកត់សម្គាល់ថារបាយការណ៍ពិភពលោកស្តីពីជនពិការប៉ាន់ប្រមាណថា* ១៥ភាគរយនៃប្រជាជនកំពុងរស់នៅជាមួយទម្រង់ពិការមួយចំនួនដែលនៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិកមានជនពិការ ៦៥០លាននាក់ ហើយ ៨០ភាគរយក្នុងចំណោមពួកគេកំពុងរស់នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍។[៣]

*ដោយស្វាគមន៍* ចំពោះភាពរីកចំរើនដែលសម្រេចបានដោយសមាជិកនិងសមាជិកធម្មតារបស់ អេស្កាប់ នៅក្នុងរយៈពេលពីរទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក១៩៩៣-២០១២ នៅក្នុងការបង្កើតមូលដ្ឋានគ្រឹះសម្រាប់វិធីសាស្រ្តមួយដែលមានមូលដ្ឋានលើសិទ្ធិឆ្ពោះទៅរកការអភិវឌ្ឍន៍ ដែលរាប់បញ្ចូលជនពិការជាមួយការផ្តោតទៅលើសេចក្តីថ្លៃថ្នូររបស់ជនពិការ ជាពិសេសតាមរយៈគោលនយោបាយ និងកិច្ចប្រឹងប្រែងក្នុងកម្រិតស្ថាប័ននិងភាពរីកចំរើនថ្មីៗនៅក្នុងនីតិកម្ម និងការលើកកម្ពស់សមត្ថភាព។

*ដោយកត់សម្គាល់ជាមួយនឹងការកោតសរសើរ* អំពីការរួមចំណែករបស់សង្គមស៊ីវិល ជាពិសេសរបស់អង្គការជនពិការ និងអង្គការសម្រាប់ជនពិការ ចំពោះភាពរីកចំរើនដែលសម្រេចបានដែលរួមបញ្ចូលទាំងតាមរយៈការលើកកម្ពស់ការយល់ដឹងជាបន្តបន្ទាប់អំពីសិទ្ធិរបស់ជនដែលមានពិការភាពផ្សេងៗគ្នា ការកែលម្អទម្លាប់អនុវត្តន៍ល្អ និងការចូលរួមក្នុងកិច្ចសន្ទនានយោបាយ។

*ដោយចងចាំថា* បណ្តាអ្នកដឹកនាំក្នុងតំបន់ប៉ាស៊ីហ្វិកនៅក្នុងវេទិកាកោះប៉ាស៊ីហ្វិកលើកទីសែសិបមួយនៅក្នុងទីក្រុងព័រវីឡា តាមរយៈសេចក្តីថ្លែងការរបស់គេ នៅថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១០[៤] បានអះអាងបញ្ជាក់សារជាថ្មីពីការគាំទ្រពេញទំហឹងរបស់ខ្លួនចំពោះយុទ្ធសាស្រ្តតំបន់ប៉ាស៊ីហ្វិកស្តីពីជនពិការ ២០១០-២០១៥[៥] ដើម្បីការពារនិងលើកកម្ពស់សិទ្ធិរបស់ជនពិការនិងផ្តល់ក្របខណ្ឌមួយសម្រាប់ការសម្របសម្រួលនៅក្នុងការកសាងតំបន់ប៉ាស៊ីហ្វិកមួយ ដែលរាប់បញ្ចូលជនពិការ និងដើម្បីពង្រឹងកិច្ចខិតខំប្រឹងប្រែងរបស់ភាគីពាក់ព័ន្ធនៅក្នុងការអនុវត្តន៍អនុសញ្ញាស្តីពីសិទ្ធិជនពិការ និងលិខិតុបករណ៍សិទ្ធិមនុស្សផ្សេងៗទៀតដែលពាក់ព័ន្ធនឹងជនពិការ។

*ដោយកត់សម្គាល់ជាមួយការកោតសរសើរ* នូវសេចក្តីប្រកាសក្រុងបាលីស្តីពីការកែលម្អតួនាទី និងការចូលរួមរបស់ជនពិការក្នុងសហគមន៍អាស៊ាន[៦] ដែលត្រូវបានអនុម័តដោយកិច្ចប្រជុំកំពូលអាស៊ានលើកទី១៩ នៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១១ ដែលរៀបចំឡើងនៅទីក្រុងបាលីប្រទេសឥណ្ឌូនេស៊ីដែលក្នុងនោះអាស៊ានបានប្រកាសថារយៈពេល២០១១-២០២០ គឺជាទសវត្សរ៍ជនពិការអាស៊ាន ដែលសំដៅរកការធានាឲ្យមានការចូលរួមដោយប្រសិទ្ធភាពរបស់ជនពិការនិងដាក់បញ្ចូលទស្សនវិស័យនៃជនពិការទៅក្នុងគោលនយោបាយ និងកម្មវិធីនានារបស់អាស៊ាន ទៅក្នុងសសរស្តំនៃសហគមន៍អាស៊ានរួមមាន ផ្នែកសេដ្ឋកិច្ច សន្តិសុខ នយោបាយ និងសង្គមវប្បធម៌។

*ដោយស្វាគមន៍* ចំពោះភាពជាដៃគូប៊ូសានដើម្បីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព[៧] ដែលត្រូវបានអនុម័តនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១១ ដោយវេទិកាកម្រិតខ្ពស់លើកទីបួនស្តីពីប្រសិទ្ធភាពនៃជំនួយនៅទីក្រុងប៊ូសានសាធារណរដ្ឋកូរ៉េ បានទទួលស្គាល់ពីសារៈសំខាន់នៃការប្តេជ្ញាចិត្តជាអន្តរជាតិស្តីអំពីជនពិការដើម្បីបង្កើតជាមូលដ្ឋានគ្រឹះនៃកិច្ចសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព។

---

[៣] អង្គការសុខភាពពិភពលោក/ធនាគារពិភពលោក, *របាយការណ៍ពិភពលោកស្តីពីជនពិការ* (ហ្សឺណែវ៖ អង្គការសុខភាពពិភពលោក ២០១១)ទំព័រ ២៩

[៤] មើល www.forumsec.org/resources/uploads/attachments/documents/2010_Forum_Communique.pdf

[៥] លេខាធិការដ្ឋានវេទិកាកោះប៉ាស៊ីហ្វិក, ឯកសារ PIFS(09)FDMM.07 (មាននៅក្នុងwww.forumsec.org.fj)

[៦] មើលwww.aseansec.org/documents/19th%20summit/Bali_Declaration_on_Disabled_Person.pdf

[៧] មើលwww.aideffectiveness.org/busanhlf4/images/stories/hlf4/OUTCOME_DOCUMENT_-_FINAL_EN.pdf

*ដោយស្វាគមន៍ផងដែរ* ចំពោះសេចក្តីប្រកាសក្រុងប៉េកាំងស្តីពីការអភិវឌ្ឍន៍ដែលរាប់បញ្ចូលជនពិការ[៨]បាន អនុម័តនៅថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១២ ដោយវេទិកាក្រុងប៉េកាំង ជាមួយប្រធានបទ "ដកចេញនូវឧបសគ្គរាំង លើកកម្ពស់ការធ្វើសមាហរណកម្ម" ដែលបានទទួលស្គាល់ពីសារៈសំខាន់ លើការបង្កើនល្បឿននៃការផ្តល់សច្ចាប័ន និងការអនុវត្តន៍អនុសញ្ញាស្តីពីសិទ្ធិជនពិការ និងការដាក់បញ្ចូលភាពសំខាន់នៃជនពិការទៅក្នុងរបៀបវារៈអភិវឌ្ឍន៍ របស់អង្គការសហប្រជាជាតិក្រោយឆ្នាំ២០១៥ នៅក្នុងផ្នែកផ្សេងៗ។

*ដោយកត់សម្គាល់* លើគោលការណ៍ណែនាំអំពីការស្តារលទ្ធភាពពលកម្មតាមសហគមន៍[៩] ដែលជា ឯកសាររួមមួយរបស់អង្គការសុខភាពពិភពលោក អង្គការពលកម្មអន្តរជាតិ អង្គការអប់រំ វិទ្យាសាស្ត្រ និង វប្បធម៌របស់អង្គការសហប្រជាជាតិ និងសហគមន៍ជនពិការនិងអភិវឌ្ឍន៍អន្តរជាតិដែលផ្តល់នូវយុទ្ធសាស្ត្រកាត់ បន្ថយភាពក្រីក្រជាលក្ខណៈពហុផ្នែក និងទូលំទូលាយមួយសម្រាប់អនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ។

*ដោយរំឭកឡើងវិញ* នូវឯកសារលទ្ធផលរបស់សន្និសីទអង្គការសហប្រជាជាតិស្តីពីការអភិវឌ្ឍន៍ប្រកបដោយ ចីរភាពដែលមានចំណងជើងថា "អនាគតដែលយើងចង់បាន"[១០] ដែលត្រូវបានអនុម័តនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១២ ហើយដែលបានកំណត់អត្តសញ្ញាណជនពិការ និងទទួលស្គាល់សិទ្ធិរាប់បញ្ចូលរបស់ពួកគេនៅក្នុង វិធានការដែលពន្លឿនការអនុវត្តកិច្ចប្តេជ្ញាអភិវឌ្ឍន៍ដែលមានចីរភាព។

*ដោយកត់សម្គាល់ជាមួយនឹងក្តីបារម្ភថា* នៅមានបញ្ហាជាច្រើនទៀតដែលត្រូវដោះស្រាយដើម្បីធានាថា ជនពិការនៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិកមានសិទ្ធិក្នុងការទទួលបានប្រកបដោយសមធម៌នូវឱកាសសេដ្ឋកិច្ច និងសង្គម ក្នុងការចូលរួមនៅក្នុងនយោបាយនិងគ្រប់ទិដ្ឋភាពផ្សេងៗទៀតនៃជីវិត។

*ដោយសង្កត់ធ្ងន់* អំពីការឆ្លើយតបលើទំហំផលវិបាករយៈពេលវែងនៃកំណើនមនុស្សចាស់ឆាប់រហ័សដែល កំពុងបន្តមាននៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក។

*ដោយកត់សម្គាល់ជាមួយនឹងក្តីបារម្ភយ៉ាងខ្លាំង* អំពីឥទ្ធិពលវិសមាមាត្រនៃគ្រោះមហន្តរាយលើជនពិការ នៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ដែលនៅក្នុងកំឡុងពេលបីទសវត្សរ៍កន្លងទៅនេះគឺជាតំបន់ដែលទទួលរងនូវ ចំនួនគ្រោះមហន្តរាយច្រើនជាងគេបំផុត។

*ដោយកត់សម្គាល់ផងដែរ* ថាអាកប្បកិរិយាជាទម្លាប់ និងអាកប្បកិរិយារើសអើងជាអវិជ្ជមាន ចំពោះជនពិការ នៅមានជាទូទៅនៅឡើយ។

*ដោយគិតដល់* ថាមានឱកាសកើនឡើងសម្រាប់លើកកម្ពស់និងការពារសិទ្ធិរបស់ជនពិការដែលរួមមាន ទាំងតាមរយៈការប្រើប្រាស់បច្ចេកវិទ្យាថ្មីៗសម្រាប់កែលម្អសិទ្ធិ និងឱកាសប្រើប្រាស់បរិស្ថានរូបវន្ត មធ្យោបាយ ដឹកជញ្ជូនសាធារណៈ ចំណេះដឹង ព័ត៌មាន និងទំនាក់ទំនង។

---

[៨] E/ESCAP/APDDP(3)/INF/5

[៩] មើលwww.who.int/disabilities/cbr/guidelines/en/index.html

[១០] មើលសេចក្តីសម្រេចរបស់អង្គមហាសន្និបាតលេខ ៦៦/២៨៨ ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០១២

១. *អនុម័ត* យុទ្ធសាស្ត្រអ៊ីនឈានដើម្បី "**ធ្វើឲ្យសិទ្ធក្លាយជាការពិត**" សម្រាប់ជនពិការនៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ដូចដែលមានភ្ជាប់ជាមួយនេះដើម្បីជំរុញសកម្មភាពដែលត្រូវពន្លឿនចក្ខុវិស័យតំបន់អំពីសង្គមមួយដែលរាប់បញ្ចូលជនពិការដែលធានាលើកកម្ពស់និងជួយគាំពារសិទ្ធិរបស់ជនពិការទាំងអស់នៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិកក្នុងកំឡុងពេលទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិកថ្មី២០១៣-២០២២។

២. *ទទួលស្គាល់* តួនាទីកណ្តាលរបស់រដ្ឋាភិបាលក្នុងការធានាលើកកម្ពស់ និងជួយគាំពារសិទ្ធិរបស់ជនពិការ ក្នុងការកែលម្អការដាក់បញ្ចូលសារៈសំខាន់នៃជនពិការ ទៅក្នុងរបៀបវារៈអភិវឌ្ឍន៍ក្រោយឆ្នាំ២០១៥ នៅក្នុងផ្នែកផ្សេងៗ។

៣. *ប្តេជ្ញា* អនុវត្តសេចក្តីប្រកាសនេះនិងយុទ្ធសាស្ត្រអ៊ីនឈាន់ ដោយជំរុញសកម្មភាពដើម្បីឈានដល់គោលដៅនិងទិសដៅអ៊ីនឈាន់ឲ្យបាននៅឆ្នាំ២០២២។

៤. *អញ្ជើញ* ភាគីពាក់ព័ន្ធទាំងអស់ដែលរួមមានដូចខាងក្រោមនេះឲ្យចូលរួមក្នុងភាពជាដៃគូថ្នាក់តំបន់ ដើម្បីចូលរួមចំណែកក្នុងការអនុវត្តន៍សេចក្តីប្រកាសនេះនិងយុទ្ធសាស្ត្រអ៊ីនឈាន់៖

ក. បណ្តាអង្គភាពអន្តររដ្ឋាភិបាលថ្នាក់អនុតំបន់ដែលរួមមានទាំងសមាគមប្រជាជាតិអាស៊ីអគ្នេយ៍អង្គការសហប្រតិបត្តិការសេដ្ឋកិច្ចវេទិការកោះប៉ាស៊ីហ្វិក និងសមាគមអាស៊ីខាងត្បូងសម្រាប់សហប្រតិបត្តិការថ្នាក់តំបន់ដើម្បីជួយលើកកម្ពស់ និងពង្រឹងកិច្ចសហប្រតិបត្តិការថ្នាក់អនុតំបន់ក្នុងការអភិវឌ្ឍន៍ដែលរាប់បញ្ចូលជនពិការនៅក្នុងកិច្ចសម្របសម្រួលជាមួយ អេស្កាប់

ខ. បណ្តាទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍ដើម្បីពង្រឹងការដាក់បញ្ចូលជនពិការទៅក្នុងគោលនយោបាយផែនការនិងកម្មវិធីនានារបស់ខ្លួន

គ. ធនាគារពិភពលោកនិងធនាគារអភិវឌ្ឍន៍អាស៊ីដើម្បីផ្តល់នូវធនធានបច្ចេកទេសនិងហិរញ្ញវត្ថុរបស់ខ្លួនសម្រាប់លើកកម្ពស់ការអភិវឌ្ឍន៍ដែលមានរួមបញ្ចូលពិការភាពនៅក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក

ឃ. ប្រព័ន្ធនៃអង្គការសហប្រជាជាតិ ដែលរួមមានកម្មវិធី មូលនិធិ ទីភ្នាក់ងារជំនាញនិងអេស្កាប់ ដើម្បីផ្តល់រួមគ្នានូវការអភិវឌ្ឍន៍ដែលរាប់បញ្ចូលពិការភាព នៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ដែលរួមមានទាំងតាមរយៈការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព នូវយន្តការដែលមានស្រាប់ក្នុងកម្រិតជាតិកម្រិតតំបន់និងកម្រិតអន្តរជាតិ ដែលមានដូចជាក្រុមអភិវឌ្ឍន៍នៃអង្គការសហប្រជាជាតិនិងបណ្តាក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេស

ង. បណ្តាអង្គការសង្គមស៊ីវិលជាពិសេសបណ្តាអង្គការជនពិការ និងអង្គការសម្រាប់ជនពិការដើម្បីចូលរួមដោយមានប្រសិទ្ធភាពនៅក្នុងការត្រួតពិនិត្យតាមដាននិងវាយតម្លៃទសវត្សរ៍ដើម្បីជំរុញឲ្យមានការឆ្លើយតបជាបន្តបន្ទាប់ចំពោះសេចក្តីប្រាថ្នានិងសេចក្តីត្រូវការរបស់ជនពិការដែលរួមមានទាំងតាមរយៈការទាក់ទងទៅកាន់ក្រុមជនពិការផ្សេងៗទៀត និងការចូលរួមចំណែកក្នុងការអភិវឌ្ឍន៍និងអនុវត្តន៍គោលនយោបាយនិងកម្មវិធី

ច. បណ្តាអង្គការជនពិការ និងអង្គការសម្រាប់ជនពិការ ដើម្បីចូលរួមដោយសកម្មនៅក្នុងដំណើរការធ្វើការសម្រេចចិត្តនានាដែលទាក់ទងទៅនឹងយុទ្ធសាស្ត្រអ៊ីនឈាន់

ឆ. ផ្នែកឯកជន ដើម្បីជួយលើកកម្ពស់ទម្លាប់អនុវត្តធុរកិច្ចដែលមានរួមបញ្ចូលវិស័យពិការភាព

៥. *ស្នើ* សុំឲ្យលេខាធិការប្រតិបត្តិរបស់ អេស្កាប់៖

ក. អនុញ្ញាតអាទិភាពចំពោះការគាំទ្រសមាជិកនិងសមាជិកធម្មតា នៅក្នុងការអនុវត្តន៍ទាំងស្រុងនិងប្រកបដោយប្រសិទ្ធភាពសេចក្តីប្រកាសនេះនិងយុទ្ធសាស្ត្រអ៊ីនឈាន់នៅក្នុងកិច្ចសហប្រតិបត្តិការជាមួយបណ្តាស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត

ខ. ចូលរួមជាមួយបណ្តាភាគីពាក់ព័ន្ធ និងលើកទឹកចិត្តឲ្យពួកគេចូលរួមក្នុងការអនុវត្តន៍សេចក្តីប្រកាសនេះនិងយុទ្ធសាស្ត្រអ៊ីនឈាន់

គ. ដាក់លទ្ធផលនៃកិច្ចប្រជុំអន្តររដ្ឋាភិបាលកម្រិតខ្ពស់នេះជូនគណៈកម្មាធិការនៅក្នុងសម័យប្រជុំលើកទីហុកសិបប្រាំបួនរបស់គណៈកម្មាធិការដើម្បីផ្តល់ការឯកភាព

ឃ. តាមរយៈប្រធាននៃអង្គមហាសន្និបាត ដាក់លទ្ធផលនៃកិច្ចប្រជុំអន្តររដ្ឋាភិបាលកម្រិតខ្ពស់នេះជូនកិច្ចប្រជុំថ្នាក់ខ្ពស់ស្តីអំពីសមិទ្ធផលនៃគោលដៅអភិវឌ្ឍន៍សហសវត្សរ៍ និងគោលដៅអភិវឌ្ឍន៍ដែលត្រូវបានព្រមព្រៀងគ្នាជាអន្តរជាតិផ្សេងៗទៀតសម្រាប់ជនពិការ នឹងត្រូវជួបប្រជុំគ្នានៅថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០១៣

ង. ធ្វើរបាយការណ៍អំពីភាពរីកចំរើន នៅក្នុងការអនុវត្តន៍សេចក្តីប្រកាសនេះនិងយុទ្ធសាស្ត្រអ៊ីនឈាន់ជូនគណៈកម្មាធិការ នៅរៀងរាល់បីឆ្នាំម្តងរហូតដល់ចុងទសវត្សរ៍

ច. អភិវឌ្ឍផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តន៍យុទ្ធសាស្ត្រអ៊ីនឈាន់ "**ធ្វើឲ្យសិទ្ធិក្លាយជាការពិត**"សម្រាប់ជនពិការ ដែលរួមមានទាំងសេចក្តីតម្រូវធ្វើរបាយការណ៍ សម្រាប់ដាក់ជូនគណៈកម្មាធិការនៅសម័យប្រជុំលើកទីចិតសិបរបស់គណៈកម្មាធិការ

៦. *ផ្តល់អនុសាសន៍* ថានៅក្នុងសម័យប្រជុំលើកទីហុកសិបប្រាំបួនរបស់ខ្លួន គណៈកម្មាធិការសម្រេច រៀបចំកិច្ចប្រជុំអន្តររដ្ឋាភិបាលថ្នាក់ខ្ពស់មួយ ដើម្បីពិនិត្យមើលឡើងវិញនូវភាពរីកចំរើនរបស់ទសវត្សរ៍នៅចំណុចពាក់កណ្តាលនៃទសវត្សរ៍(២០១៧) និងដើម្បីសន្និដ្ឋានវាយតម្លៃអំពីទសវត្សរ៍ (២០២២)។

# យុទ្ធសាស្ត្រអ៊ីនឈាន់ "ធ្វើឲ្យសិទ្ធិក្លាយជាការពិត" សម្រាប់ជនពិការ ប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក

# យុទ្ធសាស្ត្រអ៊ីនឈាន់ "ធ្វើឲ្យសិទ្ធិក្លាយជាការពិត" សម្រាប់ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក

សំដៅពន្លឿនការអភិវឌ្ឍន៍ដែលមានរួមបញ្ចូលជនពិការ និងការផ្តល់សច្ចាប័ននិងការអនុវត្តន៍អនុសញ្ញាស្តីពីសិទ្ធិជនពិការ

បានមកពីបទពិសោធន៍រយៈពេល២០ឆ្នាំ៖ ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក:១៩៩៣-២០០២ និង ២០០៣-២០១២

លក្ខណៈពិសេសជាសំខាន់៖ គោលដៅនិងទិសដៅអ៊ីនឈាន់មានលក្ខណៈកំណត់ពេលនិងអាចវាស់បាន

ផ្អែកលើគោលការណ៍នានារបស់អនុសញ្ញាស្តីពីសិទ្ធិជនពិការ

រយៈពេលកំណត់ដើម្បីសម្រេចគោលដៅនានា៖ ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ២០១៣-២០២២

សម្រាប់តំបន់អាស៊ីនិងប៉ាស៊ីហ្វិកមួយដែលមានការដាក់បញ្ចូលពិការភាពនិងភាពជាដៃគូរត្រូវតែបង្កើត៖

- ពហុផ្នែក
- ពហុភាគីពាក់ព័ន្ធ

# គោលដៅទាំង១០
# “ធ្វើអោយសិទ្ធិក្លាយជាការពិត”

**១**

កាត់បន្ថយភាពក្រីក្រ បង្កើនកិច្ចការ
និងជំរុញទស្សនវិស័យការងារ

**២**

លើកកម្ពស់ការចូលរួមក្នុងដំណើរការ
នយោបាយ និងការសម្រេចចិត្ត

**៣**

កែលម្អឱកាសប្រើប្រាស់បរិស្ថានរូបវន្ត
មធ្យោបាយដឹកជញ្ជូនសាធារណៈ
ចំណេះដឹង ព័ត៌មាន និងទំនាក់ទំនង

**៤**

ពង្រឹងកិច្ចការពារសង្គម

**៥**

ពង្រីកកិច្ចអន្តរាគមន៍និងអប់រំបឋម
របស់កុមារពិការ

**៦**

ធានាសមភាពយេនឌ័រ និងការ
លើកកម្ពស់សមត្ថភាពស្ត្រី

**៧**

ធានាការកាត់បន្ថយនិងគ្រប់គ្រង
ហានិភ័យគ្រោះមហន្តរាយដែល
មានរួមបញ្ចូលជនពិការ

**៨**

កែលម្អភាពអាចទុកចិត្តបាននិង
ភាពអាចប្រៀបធៀបបាននៃ
ទិន្នន័យជនពិការ

**៩**

ពន្លឿនការផ្តល់សច្ចាប័ននិងការអនុវត្តន៍អនុសញ្ញាស្តីពីសិទ្ធិជនពិការនិងការ
ធ្វើសុខដុមនីយកម្មនីតិកម្មជាតិជាមួយអនុសញ្ញានេះ

**១០**

ពង្រីកកិច្ចសហប្រតិបត្តិការថ្នាក់អនុ
តំបន់ ថ្នាក់តំបន់ និងថ្នាក់អន្តរតំបន់

# យុទ្ធសាស្ត្រអ៊ីនឈាន់ "ធ្វើឲ្យសិទ្ធិក្លាយជាការពិត" សម្រាប់ជនពិការ ប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក

## ក. សាវតា

១. ការកសាងយុទ្ធសាស្ត្រអ៊ីនឈាន់ "ធ្វើឲ្យសិទ្ធិក្លាយជាការពិត" សម្រាប់ជនពិការ ប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក គឺបានមកពីបទពិសោធន៍នៅក្នុងការអនុវត្តន៍ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិកចំនួនពីរលើក ជាប់ៗគ្នា១៩៩៣-២០០២ និង ២០០៣-២០១២ និងការអនុម័តជាប្រវត្តិសាស្ត្រនូវអនុសញ្ញាស្តីពីសិទ្ធិជនពិការ[១]ដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅក្នុងឆ្នាំ២០០៦។

២. ការកសាងយុទ្ធសាស្ត្រអ៊ីនឈាន់ បានទទួលផលប្រយោជន៍ពីការរួមចំណែករបស់រដ្ឋាភិបាល អង្គការជនពិការ និងអង្គការសម្រាប់ជនពិការ និងភាគីពាក់ព័ន្ធសំខាន់ៗផ្សេងទៀត។ វាបានចេញមកពីការសង្កេតព័ត៌មានគ្រឡប់ និងការយល់ច្បាស់ដែលទទួលបានតាមរយៈកិច្ចពិគ្រោះយោបល់ថ្នាក់តំបន់នានាៈ កិច្ចពិគ្រោះយោបល់ក្នុងកិច្ចប្រជុំនិងភាគីពាក់ព័ន្ធនៃក្រុមជំនាញដើម្បីពិនិត្យឡើងវិញនូវការអនុវត្តន៍ នៃទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ២០០៣-២០០១២: ក្របខណ្ឌសហសវត្សរ៍បីវ៉ាកូសម្រាប់សកម្មភាព (បាងកក ២៣-២៥ មិថុនា ២០១០) គណៈកម្មាធិការអភិវឌ្ឍន៍សង្គមនៅក្នុងសម័យប្រជុំលើកទីពីរ ( បាងកក ១៩-២១ តុលា ២០១០) កិច្ចពិគ្រោះយោបល់ភាគីពាក់ព័ន្ធថ្នាក់តំបន់ សម្រាប់កិច្ចប្រជុំអន្តររដ្ឋាភិបាលកម្រិតខ្ពស់ស្តីពីការពិនិត្យមើលឡើងវិញចុងក្រោយនូវទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក២០០៣-២០១២ (បាងកក ១៤-១៦ ធ្នូ ២០១១) និងកិច្ចប្រជុំត្រៀមថ្នាក់តំបន់សម្រាប់កិច្ចប្រជុំអន្តររដ្ឋាភិបាលកម្រិតខ្ពស់ ស្តីពីការពិនិត្យមើលឡើងវិញចុងក្រោយនូវការអនុវត្តន៍ទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក២០០៣-២០១២ (បាងកក ១៤-១៦ មីនា ២០១២)។

៣. ការឆ្លើយតបរបស់រដ្ឋាភិបាល អង្គការជនពិការ និងអង្គការសម្រាប់ជនពិការនានាចំពោះការស្ទង់មតិអំពីជនពិការប្រចាំឆ្នាំ ២០១១-២០១២ របស់ អេស្កាប់ ស្តីពីការពិនិត្យមើលឡើងវិញចុងក្រោយនូវទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិកឆ្នាំ២០០៣-២០១២ បានផ្តល់នូវមូលដ្ឋានភស្តុតាងដ៏សម្បូរបែបមួយសម្រាប់ការអភិវឌ្ឍន៍យុទ្ធសាស្ត្រអ៊ីនឈាន់។

៤. យុទ្ធសាស្ត្រអ៊ីនឈាន់ មិនមែនសំដៅចម្លងឡើងវិញនូវវិសាលភាពទូលំទូលាយរបស់ ក្របខណ្ឌសហសវត្សរ៍បីវ៉ាកូ សម្រាប់សកម្មភាព និងបីវ៉ាកូបូកប្រាំ ឆ្ពោះទៅរកសង្គមមួយដែលមានការដាក់បញ្ចូល គ្មានឧបសគ្គរាំង និងសង្គមមួយដែលឈរលើសិទ្ធិជាមូលដ្ឋានសម្រាប់ជនពិការនៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក និងអនុសញ្ញាស្តីអំពីសិទ្ធិជនពិការ ដែលនឹងបន្តប្រើជាក្របខណ្ឌនយោបាយសំខាន់សម្រាប់ការងារថ្នាក់តំបន់នៅក្នុងវិស័យពិការភាព។

ស្រដៀងគ្នាទៅនឹងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍[២] ដែលគោលដៅនិងទិសដៅអ៊ីនឈាន់គឺមានពេលវេលាកំណត់ដើម្បីពន្លឿនការអនុវត្តន៍ដោយផ្តោតការយកចិត្តទុកដាក់ជាពិសេសទៅលើការសម្រេចឲ្យបាននូវសំណុំ

---

[១] សេចក្តីសម្រេចរបស់អង្គមហាសន្និបាតលេខ ៦១/១០៦ ឧបសម្ព័ន្ធ I។

[២] គោលដៅអភិវឌ្ឍន៍សហសវត្សរ៍មាន ៨គោលដៅ ២១ទិសដៅ និង ៦០សូចនាករ។

គោលបំណងនិងគោលដៅអាទិភាពមួយនៅក្នុងកំឡុងពេលអនុវត្តទសវត្សរ៍ថ្មី២០១៣-២០២២ និងដោយជួយសម្រួលការវាស់ភាពរីកចំរើនដែលត្រូវសម្រេចឲ្យបានដោយបណ្តាប្រទេស និងដែនដីនៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក។

## ខ. ការណែនាំអំពីគោលការណ៍និងគោលនយោបាយគន្លឹះ

យុទ្ធសាស្ត្រអ៊ីនឈាន់ ឈរលើគោលការណ៍ជាមូលដ្ឋាននៃអនុសញ្ញាស្តីពីសិទ្ធិជនពិការៈ

ក. ការគោរពសេចក្តីថ្លៃថ្នូរ ស្វ័យភាពបុគ្គល ដែលរួមមានទាំងសេរីភាពធ្វើការជ្រើសរើសដោយខ្លួនឯង និងឯករាជ្យភាពនៃបុគ្គល

ខ. គ្មានការរើសអើង

គ. ការចូលរួមពេញលេញនិងប្រកបដោយប្រសិទ្ធភាព និងការរាប់បញ្ចូលក្នុងសង្គម

ឃ. ការគោរពភាពផ្សេងគ្នា និងការទទួលយកជនពិការជាផ្នែកនៃភាពចម្រុះរបស់មនុស្សជាតិ និងមនុស្សធម៌

ង. ឱកាសស្មើគ្នា

ច. ការសម្របសម្រួលសមស្រប

ឆ. សមភាពរវាងបុរសនិងស្ត្រី

ជ. ការគោរពសមត្ថភាពវិវត្តន៍របស់កុមារពិការ និងការគោរពសិទ្ធិកុមារពិការក្នុងការការពារអត្តសញ្ញាណរបស់ខ្លួន

**៧.** ដើម្បីធ្វើឲ្យសម្រេចនិងការពារនូវសិទ្ធិរបស់ជនពិការនៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក យុទ្ធសាស្ត្រអ៊ីនឈាន់សង្កត់ធ្ងន់លើការណែនាំទិសដៅនយោបាយដែលមានដូចខាងក្រោម៖

ក. វិធានការនីតិបញ្ញត្តិ រដ្ឋបាល និងវិធានការផ្សេងៗទៀតដែលគាំទ្រការបំពេញសិទ្ធិ ត្រូវបានអនុម័ត អនុវត្ត ពិនិត្យឡើងវិញ និងពង្រឹង សំដៅលុបបំបាត់ការរើសអើងចំពោះជនពិការ

ខ. គោលនយោបាយនិងកម្មវិធីអភិវឌ្ឍន៍ ដែលរាប់បញ្ចូលជនពិការនិងយកចិត្តទុកដាក់ចំពោះយេនឌ័រ និងដែលមានសក្តានុពលនៃការផ្សំ ការរចនាសាកល ជាមួយភាពរីកចំរើននៃបច្ចេកវិទ្យា ដើម្បីធ្វើឲ្យជនពិការអាចអនុវត្តសិទ្ធិរបស់ខ្លួនបាន

គ. គោលនយោបាយនិងកម្មវិធីអភិវឌ្ឍន៍ឆ្លើយតបទៅនឹងតម្រូវការជាមូលដ្ឋានរបស់ជនពិការ និងគ្រួសាររបស់ពួកគេដែលកំពុងរស់នៅក្នុងភាពក្រីក្រ

ឃ. ការប្រមូលនិងវិភាគប្រកបដោយប្រសិទ្ធភាពនិងទាន់ពេលវេលានូវទិន្នន័យជនពិការ ទៅតាមភេទ ត្រូវបានបន្តធ្វើសម្រាប់ការកសាងគោលនយោបាយដែលផ្អែកលើភស្តុតាង

ង. គោលនយោបាយនិងកម្មវិធីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់មូលដ្ឋាននានា ត្រូវបានផ្អែកទៅលើផែនការដែលរាប់បញ្ចូលជនពិការ និងដែលផ្តល់អាទិភាពដល់ការចូលរួមដោយសកម្មរបស់ជនពិការនៅក្នុងដំណើរការធ្វើការសម្រេចចិត្តដែលពាក់ព័ន្ធតាមរយៈបណ្តាអង្គការតំណាងរបស់ខ្លួន

ច. ការទ្រទ្រង់ថវិកាដែលចាំបាច់ត្រូវបានផ្តល់នៅគ្រប់ថ្នាក់ សម្រាប់កិច្ចអភិវឌ្ឍន៍ដែលមានបញ្ចូលជនពិការ ហើយគោលនយោបាយពន្ធដារជួយសម្រួលដល់ការរួមបញ្ចូលជនពិការ

ឆ. អង្គភាពថ្នាក់ជាតិ ថ្នាក់អនុតំបន់ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ដែលពាក់ព័ន្ធជាមួយការអភិវឌ្ឍន៍រួមបញ្ចូលសារៈសំខាន់នៃជនពិការទៅក្នុងគោលនយោបាយនិងកម្មវិធីនានារបស់ខ្លួន

ជ. ការសម្របសម្រួលថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងថ្នាក់តំបន់ រួមជាមួយទំនាក់ទំនងថ្នាក់អនុតំបន់ និងថ្នាក់តំបន់ ធានាថាការរួមបញ្ចូលជនពិការទៅក្នុងគោលនយោបាយនិងកម្មវិធីអភិវឌ្ឍន៍នានា ត្រូវបានពង្រឹង តាមរយៈការធ្វើឲ្យកាន់តែខ្លាំងឡើងនូវកិច្ចប្រឹក្សានិង កិច្ចសហការពហុផ្នែកដើម្បីពន្លឿននិងពិនិត្យមើលឡើងវិញនូវការអនុវត្តន៍ទសវត្សរ៍ និងចែករំលែកទម្លាប់អនុវត្តន៍ល្អៗដែលពាក់ព័ន្ធ

ឈ. ការអភិវឌ្ឍន៍ដែលមានរួមបញ្ចូលជនពិការនៅកម្រិតសហគមន៍និងកម្រិតគ្រួសារ ត្រូវបានលើកកម្ពស់ដើម្បីធានាថា ជនពិការទាំងអស់អាចចូលរួមចំណែកនិងទទួលផលប្រយោជន៍ពីការផ្តួចផ្តើមអភិវឌ្ឍនានា ជាពិសេសកម្មវិធីកាត់បន្ថយភាពក្រីក្រ ដោយឈរលើមូលដ្ឋានស្មើភាពគ្នាមួយ និងដោយមិនប្រកាន់ឋានៈសង្គមនិងសេដ្ឋកិច្ច ជំនឿសាសនា ជាតិសាសន៍ និងទីកន្លែងឡើយ

ញ. ជនពិការត្រូវបានបញ្ចូលទៅក្នុងជីវិតសហគមន៍ទូទៅ ហើយត្រូវបានគាំពារដោយមានជម្រើសជីវិតស្មើភាពគ្នាជាមួយមនុស្សដទៃទៀត ដែលរួមមានទាំងជម្រើសដើម្បីរស់នៅដោយឯករាជ្យ

ដ. ជនពិការមានសិទ្ធិនិងឱកាសប្រើប្រាស់បរិស្ថានរូបវន្ត មធ្យោបាយដឹកជញ្ជូនសាធារណៈ ចំណេះដឹង ព័ត៌មាន និងទំនាក់ទំនង នៅក្នុងរបៀបមួយដែលអាចប្រើប្រាស់បាន តាមរយៈការរចនាសាកល និងបច្ចេកវិទ្យាជាជំនួយជាមួយនឹងការផ្តល់ទីកន្លែងស្នាក់នៅសមរម្យ មានសិទ្ធិនិងយកចិត្តទុកដាក់អំពីតម្រូវការ ផ្តល់នូវទិដ្ឋភាពសេដ្ឋកិច្ច ភូមិសាស្ត្រ ភាសា និងទិដ្ឋភាពនៃភាពចម្រុះវប្បធម៌ផ្សេងៗទៀត ដែលទាំងអស់នោះបង្កើតបានជាស្ពានចម្លងសំខាន់មួយ ទៅរកការបំពេញសិទ្ធិរបស់ខ្លួន

ឋ. ក្រុមជនពិការប្រភេទផ្សេងៗគ្នា និងក្រុមដែលមិនបានរាប់បញ្ចូលនៅទីនេះត្រូវបានលើកកម្ពស់សមត្ថភាពដែលមានក្រុមតំណាងដូចខាងក្រោម៖ កុមារានិងកុមារីពិការ យុវជនពិការ ស្ត្រីពិការ ជនពិការផ្នែកសតិបញ្ញា ពិការផ្នែករៀនសូត្រនិងផ្នែកអភិវឌ្ឍន៍ ជនពិការដែលមានសតិមិនប្រក្រតី ជនពិការផ្លូវចិត្ត ជនពិការគរថ្លង់ ជនពិការភ្នែកគរថ្លង់ ជនពិការច្រើនប្រភេទ ជនពិការ ធ្ងន់ធ្ងរ ជនពិការចាស់ជរា ជនពិការដែលផ្ទុកមេរោគអេដស៍ ជនពិការដោយសារជំងឺឆ្លង ជនពិការដោយសារជំងឺឃ្លង់ ជនពិការដោយសារបញ្ហាវេជ្ជសាស្ត្រនិងជំងឺស្អុន្ធធ្ងន់ធ្ងរ ជនពិការដោយជំងឺឆ្កួតជ្រូក ជនពិការ ដោយសារគ្រោះថ្នាក់ចរាចរ ជនពិការជាអ្នកស្រុកដើមនិងជនជាតិភាគតិច ជនពិការដែលគ្មានផ្ទះសម្បែងនិងគ្មានកន្លែងស្នាក់នៅគ្រប់គ្រាន់ ជនពិការនៅក្នុងស្ថានភាពមានហានិភ័យដែលរួមមានស្ថានភាពជម្លោះប្រដាប់អាវុធស្ថានភាពត្រូវការជាបន្ទាន់នូវជំនួយមនុស្សធម៌ និងការកើតឡើងដោយគ្រោះមហន្តរាយដែលបង្កដោយធម្មជាតិនិងមនុស្ស ជនពិការដែលជាជនរងគ្រោះដោយសារគ្រាប់មីន ជនពិការដែលមិនមានឋានៈស្របច្បាប់ ជនពិការដែលជាជនរងគ្រោះដោយសារអំពើហិង្សានៅក្នុងគ្រួសារជាពិសេសស្ត្រីនិងកុមារនិងក្រុមតស៊ូមតិគ្រួសារនិងជនពិការដែលមិនត្រូវបានយកចិត្តទុកដាក់ជាពិសេសដែលរស់នៅក្នុងតំបន់ក្រីក្រតំបន់ជនបទ តំបន់ដាច់ស្រយាលនិងដែនកោះ

ឌ. បណ្តាអង្គការជនពិការ និងអង្គការសម្រាប់ជនពិការ ក្រុមជួយខ្លួនឯង និងក្រុមតស៊ូមតិខ្លួនឯង អាចចូលរួមនៅក្នុងការសម្រេចចិត្ត ទៅតាមភាពសមស្របជាមួយនឹងការទ្រទ្រង់ដែលតម្រូវដោយគ្រួសារនិងអ្នកថែទាំ ដើម្បីធានាថាផលប្រយោជន៍របស់ក្រុមដែលមិនត្រូវបានយកចិត្តទុកដាក់ត្រូវបានលើកឡើងដើម្បីដោះស្រាយបានសមល្មមគ្រប់គ្រាន់

ឍ. សកម្មភាពលើកកម្ពស់ការយល់ដឹង ត្រូវបានពង្រឹងនិងបន្តនៅក្នុងកំឡុងពេលនៃទសវត្សរ៍ ដែលរួមមានតាមរយៈការផ្តល់ការទ្រទ្រង់ផ្នែកថវិកាគ្រប់គ្រាន់ ដើម្បីកែលម្អអាកប្បកិរិយានិងឥរិយាបថ ដើម្បីកៀរគរការចូលរួមជាលក្ខណៈពហុផ្នែកប្រកបដោយប្រសិទ្ធភាពនៅក្នុងគម្រូនៃការអនុវត្តន៍។

## គ. គោលដៅនិងទិសដៅអ៊ីនឈាន់

៨. យុទ្ធសាស្ត្រអ៊ីនឈាន់ ផ្សំឡើងដោយ ១០គោលដៅពាក់ព័ន្ធ ២៧ទិសដៅ និង៦២សូចនាករ។

៩. ពេលវេលាដើម្បីសម្រេចគោលដៅនិងទិសដៅទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក២០១៣-២០២២។

១០. **គោលដៅ** ពណ៌នាពីលទ្ធផលចុងក្រោយដែលចង់បាន។ **ទិសដៅ** គឺសំដៅសម្រេចឲ្យបាននៅក្នុងពេលវេលាកំណត់មួយ។ **សូចនាករ** គឺវាស់ភាពរីកចំរើនក្នុងការឈានទៅរកទិសដៅ ហើយផ្ទៀងផ្ទាត់ថា តើទិសដៅត្រូវបានសម្រេចហើយឬនៅ។ សូចនាករមានពីរប្រភេទៈ សូចនាករស្នូល និង សូចនាករបន្ថែម[៣]។ សូចនាករទាំងពីរ គួរត្រូវបានបែងចែកតាមភេទនៅគ្រប់កន្លែងដែលអាចធ្វើបាន។

---

## គោលដៅទី ១
## កាត់បន្ថយភាពក្រីក្រ បង្កើនកិច្ចការ និងជំរុញទស្សនវិស័យការងារ

១១. ទសវត្សរ៍នេះ ត្រូវតែមានភាពរីកចំរើនបានច្រើនជាងមុននៅក្នុងការកាត់បន្ថយភាពក្រីក្រក្នុងចំណោមជនពិការ និងគ្រួសាររបស់ពួកគេ។ ជនពិការជាច្រើនមានការចាញ់ប្រៀបយ៉ាងខ្លាំងនៅលើទីផ្សារការងារ មានការចូលរួមសេដ្ឋកិច្ចតិចជាងម្ល៉ោះ ហើយមានសភាពក្រីក្រជាងអ្នកដែលមិនពិការ។ ការមានការងារសមរម្យមួយនិងការអប់រំបណ្តុះបណ្តាលនិងការគាំទ្រដែលចាំបាច់ដើម្បីរក្សាការងារនោះ គឺជាមធ្យោបាយល្អបំផុតមួយក្នុងការទប់ទល់នឹងភាពក្រីក្រ។ ដូច្នេះ អ្នកដែលអាចធ្វើការ និងចង់ធ្វើការ ត្រូវតែទទួលបានការគាំពារ ការការពារ និងការផ្គត់ផ្គង់ប្រសើរជាងមុនដើម្បីធ្វើការនេះ។ ការនេះតម្រូវឲ្យមានទីផ្សារការងារប្រសើរជាងមុន។ ការលើកកម្ពស់ជនពិការ និងគ្រួសាររបស់ពួកគេឲ្យផុតពីភាពក្រីក្រ នឹងរួមចំណែកចំពោះការសម្រេចបាននូវកំណើននៃការដាក់បញ្ចូលជនពិការ និងការអភិវឌ្ឍន៍ប្រកបដោយចីរភាព។

### ទិសដៅ ១.ក
### លុបបំបាត់ភាពក្រីក្រធ្ងន់ធ្ងរក្នុងចំណោមជនពិការ

### ទិសដៅ ១.ខ
### បង្កើនការងារសម្រាប់ជនពិការដែលមានវ័យធ្វើការដែលអាចធ្វើការ និងចង់ធ្វើការ

---

[៣] សូចនាករស្នូល ជួយសម្រួលការចែករម្លែកភាពរីកចំរើនជាអន្តរប្រទេសនៅក្នុងកំពុងពេលនៃទសវត្សថ្មី។ ទាំងនេះ គឺជាសូចនាករដែលទិន្នន័យសម្រាប់ពួកវាអាចត្រូវបានបង្កើតដោយកិច្ចប្រឹងប្រែងមួយចំនួន។ សូចនាករបន្ថែម អាចជួយសម្រួលការតាមដានភាពរីកចំរើនក្នុងបណ្តាប្រទេសនានាដែលមានលក្ខខណ្ឌអភិវឌ្ឍន៍សង្គមនិងសេដ្ឋកិច្ចស្រដៀងគ្នា និងដែលទិន្នន័យសម្រាប់វាអាចពិបាកប្រមូលជាង។

### ទិសដៅ ១.គ

### បង្កើនការចូលរួមរបស់ជនពិការក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងកម្មវិធីទ្រទ្រង់ការងារផ្សេងៗទៀត ដែលផ្តល់មូលនិធិដោយរដ្ឋាភិបាល

## សូចនាករសម្រាប់តាមដាន ភាពរីកចំរើន

### សូចនាករស្នូល

១.១ សមាមាត្រជនពិការដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រអន្តរជាតិ១.២៥ដុល្លារអាមេរិកក្នុង១ថ្ងៃ តាមការធ្វើបច្ចុប្បន្នកម្មរបស់ធនាគារពិភពលោក និងតាមការប្រៀបធៀបទៅនឹងប្រជាជនទាំងអស់

១.២ អត្រាជនពិការដែលកំពុងមានការងារធ្វើ ធៀបទៅនឹងប្រជាជនទូទៅដែលមានការងារធ្វើ

១.៣ សមាមាត្រជនពិការដែលចូលរួមក្នុងការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបណ្តាកម្មវិធីទ្រទ្រង់ការងារផ្សេងៗទៀតដែលផ្តល់មូលនិធិដោយរដ្ឋាភិបាល ធៀបនឹងចំនួនអ្នកដែលទទួលបានការបណ្តុះបណ្តាលទាំងអស់

### សូចនាការបន្ថែម

១.៤ សមាមាត្រជនពិការដែលរស់នៅក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ

# គោលដៅទី ២

# លើកកម្ពស់ការចូលរួមក្នុងដំណើរការនយោបាយ និងការសម្រេចចិត្ត

**១២.** ការចូលរួមរបស់ជនពិការក្នុងសកម្មភាពនយោបាយនិងការសម្រេចចិត្ត គឺជាការសំខាន់សម្រាប់សមិទ្ធិកម្មនៃសិទ្ធិរបស់ជនពិការ។ ការដែលអាចអនុវត្តសិទ្ធិបោះឆ្នោត និងសិទ្ធិត្រូវបានបោះឆ្នោតជ្រើសតាំង គឺមាននៅក្នុងគោលដៅនេះ។ ទសវត្សរ៍នេះ ត្រូវតែបង្ហាញភាពរីកចំរើនដែលធំនិងទូលំទូលាយជាងមុន នៅក្នុងការចូលរួមនៃក្រុមជនពិការផ្សេងៗនៅក្នុងដំណើរការនយោបាយនិងការសម្រេចចិត្តនៅគ្រប់ថ្នាក់ដែលរួមមានទាំងស្ត្រីនិងយុវជនពិការ។ លើសពីនេះទៅទៀត ការកែលម្អផ្នែកបច្ចេកវិទ្យាគួរត្រូវបានផ្តល់ ដើម្បីឲ្យជនពិការអាចចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តជាសាធារណៈ ដើម្បីអនុវត្តសិទ្ធិរបស់ខ្លួន និងបំពេញការទទួលខុសត្រូវរបស់ខ្លួនក្នុងឋានៈជាសមាជិកពេញលក្ខណៈរបស់សង្គម។ ការកែលម្អទាំងនេះ រួមបញ្ចូលការផ្តល់នូវបរិស្ថានដែលផ្តល់លទ្ធភាពដល់ជនពិការឲ្យមានឱកាសដោយសមធម៌ក្នុងការទទួលបានការតែងតាំង នៅក្នុងវិស័យយុត្តាធិការ នីតិប្រតិបត្តិ និងនីតិបញ្ញត្តិរបស់រដ្ឋាភិបាល ដែលរួមទាំងការតែងតាំងនៅក្នុងតុលាការកំពូល បណ្តាក្រសួង និងស្ថាប័ននីតិបញ្ញត្តិជាតិ។

### ទិសដៅ ២.ក

### ធានាថា ជនពិការត្រូវបានតំណាងនៅតាមបណ្តាស្ថាប័នធ្វើការសម្រេចចិត្តរបស់រដ្ឋាភិបាល

### ទិសដៅ ២.ខ
### ផ្ដល់ការសម្របសម្រួលសមស្រប ដើម្បីលើកកម្ពស់ការចូលរួមរបស់ជនពិការនៅក្នុងដំណើរការនយោបាយ

## សូចនាករសម្រាប់តាមដាន ភាពរីកចំរើន

### សូចនាករស្នូល

២.១ សមាមាត្រអាសនៈទទួលបានដោយជនពិការនៅក្នុងសភា ឬស្ថាប័ននីតិបញ្ញត្តិជាតិដែលមានតម្លៃស្មើ

២.២ សមាមាត្រសមាជិករបស់យន្តការសម្របសម្រួលជាតិអំពីជនពិការដែលតំណាងឲ្យក្រុមពិការផ្សេងៗ

២.៣ សមាមាត្រអ្នកដែលត្រូវបានតំណាងនៅក្នុងយន្តការថ្នាក់ជាតិសម្រាប់សមភាពយេនឌ័រនិងការលើកកម្ពស់សមត្ថភាពស្ត្រីដែលជាជនពិការ

២.៤ សមាមាត្រមណ្ឌលបោះឆ្នោតនៅក្នុងរាជធានីជាតិដែលអាចប្រើប្រាស់បានដោយមានដំណើរការដែលធានាការសម្ងាត់របស់អ្នកបោះឆ្នោតពិការ

### សូចនាករបន្ថែម

២.៥ សមាមាត្រជនពិការដែលកាន់កាប់មុខនាទីក្នុងខុទ្ទកាល័យជាតិ

២.៦ សមាមាត្រជនពិការដែលមានមុខនាទីជាចៅក្រមតុលាការកំពូល។

២.៧ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំបទដ្ឋានគតិយុត្ត សំរាប់ដំណើរការបោះឆ្នោតដើម្បីធ្វើឲ្យជនពិការគ្រប់ប្រភេទទាំងអស់អាចចូលរួមបាន។

---

# គោលដៅទី ៣

# កែលម្អឱកាសប្រើប្រាស់បរិស្ថានរូបវន្ត មធ្យោបាយដឹកជញ្ជូនសាធារណៈ ចំណេះដឹង ព័ត៌មាន និងទំនាក់ទំនង

**១៣.** ឱកាសប្រើប្រាស់បរិស្ថានរូបវន្ត មធ្យោបាយដឹកជញ្ជូនសាធារណៈ ចំណេះដឹង ព័ត៌មាននិងទំនាក់ទំនង គឺជាបុរលក្ខខណ្ឌសម្រាប់ជនពិការដើម្បីអនុវត្តសិទ្ធិរបស់ខ្លួន នៅក្នុងសង្គមមួយដែលរាប់បញ្ចូលពួកគេ។ ភាពអាចចេញចូលបាននៃតំបន់ទីក្រុង ជនបទ និងដាច់ស្រយាលដែលផ្អែកលើការរចនាសាកល បង្កើននូវសុវត្ថិភាពនិងភាពងាយស្រួលប្រើប្រាស់ មិនត្រឹមតែសម្រាប់ជនពិការប៉ុណ្ណោះទេ ប៉ុន្តែសម្រាប់សមាជិកទាំងអស់ផ្សេងទៀតរបស់សង្គមផងដែរ។ ការពិនិត្យលើឱកាសប្រើប្រាស់ គឺជាមធ្យោបាយសំខាន់មួយក្នុងការធានាពីភាពអាចប្រើប្រាស់បាន ហើយចាំបាច់ត្រូវគ្របដណ្ដប់លើគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការរៀបចំផែនការ រចនា សាងសង់ថែទាំ និងត្រួតពិនិត្យតាមដាននិងវាយតម្លៃ។ ឱកាសប្រើប្រាស់ឧបករណ៍ជំនួយ និងសេវាកម្មទ្រទ្រង់ដែលពាក់ព័ន្ធ ក៏ជាបុរលក្ខខណ្ឌមួយផងដែរសម្រាប់ជនពិការ ដើម្បីធ្វើឲ្យប្រសើរបំផុតនូវកម្រិតឯករាជ្យភាពរបស់ខ្លួននៅក្នុងជីវិតប្រចាំថ្ងៃ និងដើម្បីអាចរស់នៅបានក្នុងសេចក្ដីថ្លៃថ្នូរ។ ការធានាភាពមាននៃឧបករណ៍ជំនួយសម្រាប់អ្នក

ដែលរស់នៅក្នុងតំបន់ដែលមានធនធានតិច ពាក់ព័ន្ធទៅនឹងការលើកទឹកចិត្តឲ្យមានការសិក្សាស្រាវជ្រាវ អភិវឌ្ឍ ផលិត ចែកចាយ និងថែទាំ។

**ទិសដៅ ៣.ក**

**បង្កើនឱកាសប្រើប្រាស់បរិស្ថានរូបវន្តនៅក្នុងរាជធានីជាតិដែលបើកចំហរចំពោះសាធារណជន**

**ទិសដៅ ៣.ខ**

**កែលម្អឱកាសប្រើប្រាស់និងភាពអាចប្រើប្រាស់បាននៃសេវាដឹកជញ្ជូនសាធារណៈ**

**ទិសដៅ៣.គ**

**កែលម្អឱកាសប្រើប្រាស់និងភាពអាចប្រើប្រាស់បាននៃសេវាព័ត៌មាននិងទំនាក់ទំនង**

**ទិសដៅ ៣.ឃ**

**ពាក់កណ្តាលនៃសមាមាត្រជនពិការដែលត្រូវការឧបករណ៍ឬផលិតផលជំនួយសមស្រប ប៉ុន្តែមិនមានឧបករណ៍ឬផលិតផលទាំងនោះ**

---

## សូចនាករសម្រាប់តាមដានភាពរីកចំរើន

### សូចនាករស្នូល

៣.១ សមាមាត្រអគាររដ្ឋាភិបាលដែលអាចចេញចូលបាននៅក្នុងរាជធានីជាតិ

៣.២ សមាមាត្រអាកាសយានដ្ឋានអន្តរជាតិដែលអាចចេញចូលបាន

៣.៣ សមាមាត្រការដាក់ចំណងជើងនិងបកប្រែភាសាសញ្ញាប្រចាំថ្ងៃរបស់កម្មវិធីព័ត៌មានតាមទូរទស្សន៍សាធារណៈ

៣.៤ សមាមាត្រឯកសារនិងគេហទំព័រសាធារណៈដែលអាចចេញចូលនិងប្រើប្រាស់បាន ដែលស្របនឹងនិយាមនៃភាពអាចចេញចូលប្រើប្រាស់បានដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិ

៣.៥ សមាមាត្រជនពិការដែលត្រូវការឧបករណ៍ឬផលិតផលជំនួយហើយមានឧបករណ៍ឬផលិតផលទាំងនោះ

### សូចនាករបន្ថែម

៣.៦ មានកម្មវិធីត្រួតពិនិត្យច្រកចេញចូលរបស់រដ្ឋាភិបាលដែលតម្រូវឲ្យមានការចូលរួមរបស់អ្នកជំនាញដែលជាជនពិការ

៣.៧ មាននិយាមបច្ចេកទេសចាំបាច់សម្រាប់ឱកាសប្រើប្រាស់ដែលគ្មានឧបសគ្គរាំង ដែលគ្រប់គ្រងលើការឯកភាពក្នុងការរចនាអគារទាំងអស់ដែលអាចប្រើប្រាស់បានដោយសាធារណជន ក្នុងការពិចារណាអំពីនិយាមដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិដូចជាបទដ្ឋានរបស់អង្គការកំណត់បទដ្ឋានអន្តរជាតិ (ISO)ជាដើម

៣.៨ ចំនួនអ្នកបកប្រែភាសាសញ្ញា

៣.៩ មាននិយាមបច្ចេកទេសចាំបាច់សម្រាប់ឱកាសប្រើប្រាស់គ្មានឧបសគ្គរាំងដែលគ្រប់គ្រងលើការឯកភាពនៃសេវាដែលទាក់ទងនឹងបច្ចេកវិទ្យាទំនាក់ទំនងព័ត៌មានវិទ្យាទាំងអស់ ដូចជាគេហទំព័រសម្រាប់សាធារណជនជាដើម ដោយពិចារណាអំពីនិយាមដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិដូចជាបទដ្ឋានរបស់អង្គការកំណត់បទដ្ឋានអន្តរជាតិ(ISO)ជាដើម។

---

# គោលដៅទី ៤

## ពង្រឹងកិច្ចការពារសង្គម

**១៤.** វិសាលភាពនៃកិច្ចការពារសង្គមនៅក្នុងប្រទេសកំពុងអភិវឌ្ឍក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិកជាញឹកញាប់ត្រូវបានកំណត់ត្រឹមជាកម្មវិធីធានារ៉ាប់រងសង្គម និងមានតែចំពោះអ្នកដែលមានកិច្ចសន្យាការងារទៀងទាត់នៅក្នុងផ្នែកជាក់លាក់ប៉ុណ្ណោះ ហើយទុកឲ្យប្រជាជនភាគច្រើនគ្មានការការពារគ្រប់គ្រាន់ឡើយជាពិសេសជនពិការ។ ដូច្នេះវាជាការសំខាន់ណាស់ដែលត្រូវធានាថា ជនពិការមានសិទ្ធិនិងឱកាសទទួលបានកិច្ចការពារសង្គមនៅលើមូលដ្ឋានស្មើភាពគ្នាមួយជាមួយអ្នកដទៃទៀត ហើយវាគឺជាការសំខាន់ដែលត្រូវលើកកម្ពស់កម្រិតកិច្ចការពារសង្គមជាបន្ថែមទៀតជាមួយនឹងការផ្តោតការយកចិត្តទុកដាក់មួយទៅលើការថែទាំសុខភាពនិងការការពារប្រាក់ចំណូលមូលដ្ឋានសម្រាប់ទាំងអស់គ្នា។ជាងនេះទៅទៀតនៅមានកង្វះខាតសេវាដែលអាចប្រើប្រាស់បានដែលរួមមានទាំងជំនួយផ្ទាល់ខ្លួននិងសេវាប្រឹក្សាមិត្តដែលអាចជួយឲ្យជនពិការរស់នៅបានដោយឯករាជ្យនៅក្នុងសហគមន៍។ សម្រាប់ជនពិការជាច្រើនសេវាទាំងនេះមានលក្ខណៈចាំបាច់សម្រាប់ការចូលរួមរបស់ពួកគេនៅក្នុងសង្គម។

### ទិសដៅ ៤.ក

**បង្កើនឱកាសប្រើប្រាស់សេវាសុខភាពទាំងអស់ ដែលរួមទាំងការស្តារលទ្ធភាពពលកម្ម សម្រាប់ជនពិការទាំងអស់**

### ទិសដៅ ៤.ខ

**បង្កើនវិសាលភាពនៃជនពិការនៅក្នុងបណ្តាកម្មវិធីកិច្ចការពារសង្គម**

### ទិសដៅ ៤.គ

**លើកកម្ពស់សេវានិងកម្មវិធី ដែលរួមមានទាំងសម្រាប់ជំនួយផ្ទាល់ខ្លួននិងសេវាប្រឹក្សាមិត្តដែលជួយទ្រទ្រង់ដល់ជនពិការ ជាពិសេសជនពិការច្រើនប្រភេទ ពិការធ្ងន់ធ្ងរនិងពិការផ្សេងៗនៅក្នុងការរស់នៅដោយឯករាជ្យនៅក្នុងសហគមន៍។**

---

សូចនាករសម្រាប់តាមដាន ភាពរីកចំរើន

សូចនាករស្នូល

៤.១ សមាមាត្រជនពិការដែលប្រើប្រាស់កម្មវិធីថែទាំសុខភាពដែលទ្រទ្រង់ដោយរដ្ឋាភិបាល ធៀបទៅនឹងប្រជាជនទូទៅ។

៤.២ វិសាលភាពនៃជនពិការ នៅក្នុងបណ្តាកម្មវិធីកិច្ចការពារសង្គមដែលរួមមានទាំងកម្មវិធីធានារ៉ាប់រងសង្គម និងកម្មវិធីជំនួយសង្គម

៤.៣ មានសេវានិងកម្មវិធីដែលផ្តល់មូលនិធិដោយរដ្ឋាភិបាល ដែលរួមមានទាំងសម្រាប់ជំនួយផ្ទាល់ខ្លួន និងសេវាប្រឹក្សាមិត្តដែលអាចឲ្យជនពិការរស់នៅដោយឯករាជ្យនៅក្នុងសហគមន៍

សូចនាករបន្ថែម

៤.៤ ចំនួនកម្មវិធីដែលទ្រទ្រង់ដោយរដ្ឋាភិបាលសម្រាប់សេវាថែទាំដែលរួមមានទាំងសម្រាប់ការថែទាំក្នុងរយៈពេលវៀងទាត់ណាមួយ។

៤.៥ មានកម្មវិធីជាតិស្តារលទ្ធភាពពលកម្មតាមសហគមន៍ថ្នាក់ជាតិ

៤.៦ មានការធានារ៉ាប់រងសុខភាពសម្រាប់ជនពិការ

៤.៧ ការថយចុះនៅក្នុងតម្រូវការចំពោះសេវាជំនួយនិងទ្រទ្រង់ដែលមិនបានបំពេញ

## គោលដៅទី ៥
## ពង្រីកកិច្ចអន្តរាគមន៍និងអប់រំបឋមរបស់កុមារពិការ

**១៥.** មានការធ្វេសប្រហែលខ្លះលើបញ្ហាអភិវឌ្ឍន៍យឺតនិងបញ្ហាពិការនៅក្នុងចំណោមកុមារ ដែលពួកគេភាគច្រើនគឺជាកុមារក្នុងគ្រួសារដែលរស់នៅក្នុងភាពក្រីក្រ។ នៅក្នុងភាគច្រើននៃតំបន់អាស៊ីនិងប៉ាស៊ីហ្វិក មានចំនួនវិសមាមាត្រមួយនៃកុមារពិការដែលមិនមានឱកាសទទួលបានកិច្ចអន្តរាគមន៍និងកម្មវិធីអប់រំបឋម។ ការរកឃើញដំបូងនៃភាពយឺតយ៉ាវនៅក្នុងការឈានដល់គោលដៅអភិវឌ្ឍន៍គឺមានលក្ខណៈសំខាន់ដូចជាការវាស់ដោយទៀងទាត់នូវកម្ពស់និងទម្ងន់របស់ទារកនិងកុមារដែរ។ បន្ទាប់ពីការរកឃើញដំបូងនៃភាពយឺតយ៉ាវនៅក្នុងការឈានដល់គោលដៅអភិវឌ្ឍន៍ វាជាការចាំបាច់ដែលត្រូវផ្តល់ការឆ្លើយតបភ្លាមៗនិងសមស្រប ដើម្បីធ្វើឲ្យការអភិវឌ្ឍន៍គ្រប់ផ្នែករបស់ពួកគេបានប្រសើរបំផុត។ ការឆ្លើយតបជាកិច្ចអន្តរាគមន៍ដំបូងទាំងនេះ មានវិសាលភាពគ្របលើការលើកកម្លាំងចិត្ត ការអប់រំ និងថែទាំ និងការអប់រំមុនចូលសាលា។ ការវិនិយោគនៅក្នុងកម្មវិធីកុមារភាពដំបូងផ្តល់នូវលទ្ធផលប្រសើរជាងកម្រិតបន្ទាប់នៃការអប់រំនិងបណ្តុះបណ្តាល។ កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលចំពោះកម្មវិធីកុមារភាពដំបូងនេះ នឹងធ្វើឲ្យលទ្ធផលអភិវឌ្ឍន៍របស់ពួកគេកាន់តែប្រសើរឡើង។ ជាងនេះទៅទៀត វាជាការសំខាន់សម្រាប់រដ្ឋាភិបាលក្នុងការធានាថាកុមារពិការមានឱកាសទទួលបានការអប់រំថ្នាក់បឋមសិក្សានិងអនុវិទ្យាល័យដែលមានគុណភាពនៅលើមូលដ្ឋានសមធម៌មួយជាមួយកុមារផ្សេងៗទៀត នៅក្នុងសហគមន៍ដែលខ្លួនរស់នៅ។ ដំណើរការនេះរួមបញ្ចូលការធ្វើឲ្យគ្រួសារក្លាយជាដៃគូនៅក្នុងការផ្តល់ការគាំពារដែលមានប្រសិទ្ធភាពជាងមុនសម្រាប់កុមារពិការ។

**ទិសដៅ ៥.ក**

**កែលម្អវិធានការសម្រាប់ការរកឃើញនិងកិច្ចអន្តរាគមន៍បឋម សម្រាប់កុមារពិការ ចាប់ពីថ្ងៃកើតរហូតដល់អាយុត្រៀមចូលរៀន**

**ទិសដៅ ៥.ខ**

**ពាក់កណ្ដាលនៃគម្លាតអត្រាចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សា និងថ្នាក់អនុវិទ្យាល័យ រវាងកុមារពិការ និងកុមារមិនពិការ**

---

## សូចនាករសម្រាប់តាមដាន ភាពរីកចំរើន

### សូចនាករស្នូល

៥.១ ចំនួនកុមារពិការដែលទទួលបានកិច្ចអន្តរាគមន៍បឋមសម្រាប់កុមារភាព

៥.២ អត្រាចុះឈ្មោះចូលរៀនថ្នាក់បឋមសិក្សារបស់កុមារពិការ

៥.៣ អត្រាចុះឈ្មោះចូលរៀនថ្នាក់អនុវិទ្យាល័យរបស់កុមារពិការ

### សូចនាករបន្ថែម

៥.៤ សមាមាត្រទីកន្លែងឬសេវាកម្មថែទាំសាធារណៈនៅមុននិងក្រោយពេលកើត ដែលផ្ដល់នូវព័ត៌មាននិងសេវាដែលទាក់ទងទៅនឹងការរកឃើញដំបូងនូវភាពពិការរបស់កុមារនិងការការពារសិទ្ធិរបស់កុមារពិការ

៥.៥ សមាមាត្រកុមារថ្លង់ដែលទទួលបានការបង្រៀនភាសាសញ្ញា

៥.៦ សមាមាត្រសិស្សដែលពិការភ្នែកដែលមានសម្ភារៈសិក្សាក្នុងទម្រង់ដែលអាចប្រើប្រាស់បាន

៥.៧ សមាមាត្រសិស្សដែលពិការផ្នែកបញ្ញានិងអភិវឌ្ឍន៍ ពិការភ្នែកគថ្លង់ ជនពិការសតិមិនប្រក្រតី និងពិការភាពផ្សេងៗទៀតដែលមានឧបករណ៍ជំនួយ កម្មវិធីសិក្សា និងសម្ភារៈសិក្សាដែលសមស្រប

---

# គោលដៅទី ៦

# ធានាសមភាពយេនឌ័រនិងការលើកកម្ពស់សមត្ថភាពស្ត្រី

**១៦.** ក្មេងស្រីនិងស្ត្រីពិការ ប្រឈមមុខទៅនឹងទម្រង់រើសអើងនិងរំលោភបំពានជាច្រើន។ ភាពឯកកោរួមផ្សំជាមួយភាពពឹងផ្អែកលើអ្នកថែទាំ ធ្វើឲ្យពួកគេងាយរងគ្រោះបំផុតដោយសារទម្រង់នៃការធ្វើអាជីវកម្មអំពើហិង្សានិងការរំលោភបំពានជាមួយនឹងហានិភ័យដែលអាចកើតមាននៅពេលបន្ទាប់ ដែលរួមមានទាំងការឆ្លងវីរុសហ៊ីវ ការមានគភ៌ និងមរណភាពមាតានិងទារក។ ក្មេងស្រីនិងស្ត្រីពិការភាគច្រើន មិនឃើញមាននៅក្នុងកម្មវិធីសមភាពយេនឌ័រទូទៅឡើយ។ ព័ត៌មានពាក់ព័ន្ធនឹងសុខភាពផ្លូវភេទនិងបន្តពូជ ការថែទាំសុខភាពទូទៅ និងសេវាដែលពាក់ព័ន្ធមិនសូវមានជាទម្រង់និងភាសាដែលពួកគេអាចប្រើប្រាស់បានឡើយ។ សេចក្ដីសន្យាពិតប្រាកដរបស់ទសវត្សរ៍នេះ

នឹងសម្រេចទាំងស្រុងបានតែនៅពេលដែលក្មេងស្រីនិងស្ត្រីពិការគឺជាអ្នកចូលរួមយ៉ាងសកម្មនៅក្នុងការអភិវឌ្ឍន៍ប៉ុណ្ណោះ។

**ទិសដៅ ៦.ក**
**ធ្វើឲ្យក្មេងស្រីនិងស្ត្រីពិការទទួលបានដោយសមធម៌នូវឱកាសអភិវឌ្ឍន៍**

**ទិសដៅ ៦.ខ**
**ធានាឲ្យមានអ្នកតំណាងក្មេងស្រីនិងស្ត្រីពិការ នៅក្នុងស្ថាប័នធ្វើការសម្រេចចិត្តនៃរដ្ឋាភិបាល**

**ទិសដៅ ៦.គ**
**ធានាថា ក្មេងស្រីនិងស្ត្រីពិការទាំងអស់មានសិទ្ធិនិងឱកាសទទួលបានសេវាសុខភាពផ្លូវភេទនិងបន្តពូជនៅលើមូលដ្ឋានសធម៌មួយជាមួយនឹងក្មេងស្រីនិងស្ត្រីដែលមិនពិការ**

**ទិសដៅ ៦.ឃ**
**បង្កើនវិធានការដើម្បីការពារក្មេងស្រីនិងស្ត្រីពិការពីអំពើហិង្សានិងការរំលោភបំពានគ្រប់រូបភាពទាំងអស់។**

## សូចនាករសម្រាប់តាមដានភាពរីកចំរើន

### សូចនាករស្នូល

៦.១ ចំនួនប្រទេសដែលដាក់បញ្ចូលការលើកកម្ពស់ការចូលរួមរបស់ក្មេងស្រីនិងស្ត្រីពិការទៅក្នុងផែនការសកម្មភាពជាតិស្តីពីសមភាពយេនឌ័រនិងការលើកកម្ពស់សមត្ថភាពស្ត្រីរបស់ខ្លួន

៦.២ សមាមាត្រអាសនៈដែលទទួលបានដោយស្ត្រីពិការនៅក្នុងសភា ឬស្ថាប័ននីតិបញ្ញត្តិជាតិដែលមានតម្លៃស្មើ

៦.៣ សមាមាត្រក្មេងស្រីនិងស្ត្រីពិការដែលមានឱកាសទទួលបានសេវាសុខភាពផ្លូវភេទនិងបន្តពូជរបស់រដ្ឋាភិបាលនិងសង្គមស៊ីវិល ធៀបទៅនឹងស្ត្រីនិងក្មេងស្រីដែលមិនពិការ

៦.៤ ចំនួនកម្មវិធីដែលផ្តួចផ្តើមដោយរដ្ឋាភិបាលនិងភ្នាក់ងារពាក់ព័ន្ធ ដែលសំដៅលុបបំបាត់អំពើហិង្សាដែលរួមទាំងការរំលោភបំពាននិងការធ្វើអាជីវកម្មផ្លូវភេទ ដែលប្រព្រឹត្តទៅលើក្មេងស្រីនិងស្ត្រីពិការ

៦.៥ ចំនួនកម្មវិធីដែលផ្តួចផ្តើមដោយរដ្ឋាភិបាលនិងភ្នាក់ងារពាក់ព័ន្ធ ដែលផ្តល់ការថែទាំនិងការគាំពារដែលរួមមានទាំងការស្តារលទ្ធភាពពលកម្ម សម្រាប់ស្ត្រីនិងក្មេងស្រីពិការដែលជាជនរងគ្រោះដោយសារទម្រង់ណាមួយនៃអំពើហិង្សានិងការរំលោភបំពាន

# គោលដៅទី ៧

## ធានាការកាត់បន្ថយនិងគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយដែលមានរួមបញ្ចូលជនពិការ

**១៧.** តំបន់អាស៊ីនិងប៉ាស៊ីហ្វិក គឺជាតំបន់ដែលទទួលរងគ្រោះអាក្រក់បំផុតដោយសារគ្រោះមហន្តរាយផ្សេងៗ ដែលរួមមានទាំងមហន្តរាយបង្កឡើងដោយការប្រែប្រួលអាកាសធាតុ។ ជនពិការនិងក្រុមងាយរងគ្រោះផ្សេងទៀតមានហានិភ័យកាន់តែខ្ពស់អំពីការស្លាប់ ការរងរបួស និងរងភាពពិការបន្ថែម ដែលជាលទ្ធផលមួយនៃការផាត់ពួកគេចេញពីគោលនយោបាយផែនការ និងកម្មវិធីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ ការប្រកាសនៃសេវាសាធារណៈនានាជាញឹកញាប់ត្រូវបានចេញក្នុងទម្រង់និងភាសាដែលជនពិការមិនអាចយល់ឬប្រើប្រាស់បាន។ បន្ថែមលើសពីនេះទៅទៀត ច្រកចេញ ជម្រក និងសម្ភារៈដោះស្រាយនៅគ្រាមានអាសន្ន មិនទំនងជាគ្មានឧបសគ្គរាំងនោះឡើយ។ ការចូលរួមទៀងទាត់របស់ជនពិការនៅក្នុងលំហាត់រៀបចំនៅគ្រាមានអាសន្ននិងវិធានការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយផ្សេងៗទៀតនៅកម្រិតមូលដ្ឋាននិងស្រុក អាចបង្ការនិងកាត់បន្ថយជាអតិបរមានូវហានិភ័យ និងការខូចខាតនៅពេលមានគ្រោះមហន្តរាយកើតឡើង។ ហេដ្ឋារចនាសម្ព័ន្ធជារូបវន្តនិងព័ត៌មានដែលដាក់បញ្ចូលនូវគោលការណ៍រចនាសាកល អាចនឹងកែលម្អឱកាសទទួលបានសុវត្ថិភាពនិងការរស់រានមានជីវិត។

### ទិសដៅ ៧.ក

**ពង្រឹងផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ដោយដាក់បញ្ចូលជនពិការ។**

### ទិសដៅ ៧.ខ

**ពង្រឹងការអនុវត្តន៍វិធានការផ្តល់ការគាំពារដល់ជនពិការឲ្យបានទាន់ពេលនិងសមស្របក្នុងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ។**

---

## សូចនាករសម្រាប់តាមដាន ភាពរីកចំរើន

### សូចនាករស្នូល

៧.១ មានផែនការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយដែលមានដាក់បញ្ចូលជនពិការ

៧.២ មានការបណ្តុះបណ្តាលដែលដាក់បញ្ចូលជនពិការសម្រាប់បុគ្គលិកសេវាពាក់ព័ន្ធទាំងអស់

៧.៣ សមាមាត្រជម្រកសម្រាប់គ្រាមានអាសន្ន និងកន្លែងសម្រាលទុក្ខនៅគ្រាមានគ្រោះមហន្តរាយដែលអាចទទួលនិងប្រើប្រាស់បាន

### សូចនាករបន្ថែម

៧.៤ ចំនួនជនពិការដែលបានស្លាប់និងរងរបួសធ្ងន់ធ្ងរនៅក្នុងគ្រោះមហន្តរាយនានា

៧.៥ មានបុគ្គលិកសេវាទ្រទ្រង់ចិត្តសាស្ត្រនិងសង្គមដែលមានសមត្ថភាពជួយជនពិការដែលរងគ្រោះដោយសារគ្រោះមហន្តរាយ

៧.៦ មានឧបករណ៍និងបច្ចេកវិទ្យាជំនួយសម្រាប់ជនពិការក្នុងការរៀបចំ និងឆ្លើយតបចំពោះគ្រោះមហន្តរាយ

## គោលដៅទី ៨

## កែលម្អភាពអាចទុកចិត្តបាននិងភាពអាចប្រៀបធៀបបាននៃទិន្នន័យជនពិការ

**១៨.** ជនពិការទំនងជាមិនត្រូវបានមើលឃើញស្តាប់ឮនិងរាប់បញ្ចូលឡើយ។ ជាច្រើនឆ្នាំកន្លងទៅថ្មីៗនេះ នៅពេលពួកគេមិនត្រូវបានរាប់ និយមន័យនៃពាក្យ "ពិការភាព" និង "ជនពិការ" ត្រូវបានប្រើសម្រាប់ប្រមូលទិន្នន័យជនពិការបានប្រែប្រួលយ៉ាងខ្លាំងនៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក។ បើយកទិន្នន័យទាំងនោះមកធ្វើការជាមួយគ្នាការប្រៀបធៀបទិន្នន័យរវាងប្រទេសខ្លះជាញឹកញាប់គឺមិនអាចជឿទុកចិត្តបានឡើយ។ តំបន់អាស៊ីនិងប៉ាស៊ីហ្វិក ត្រូវការស្ថិតិដែលមានភាពសុក្រឹតជាងមុនស្តីអំពីប្រជាជនពិការផ្សេងៗ និងអំពីឋានៈសង្គមនិងសេដ្ឋកិច្ចរបស់ពួកគេ។ ភាពគ្រប់ជ្រុងជ្រោយនៃស្ថិតិអំពីជនពិការនឹងធ្វើឲ្យការធ្វើគោលនយោបាយមានលក្ខណៈផ្អែកលើភស្តុតាងដើម្បីគាំទ្រសមិទ្ធិកម្មនៃសិទ្ធិរបស់ជនពិការ។ ទសវត្សរ៍នេះគឺជាឱកាសមួយដើម្បីកែលម្អការប្រមូលទិន្នន័យដែលសំដៅទៅរកការបង្កើតស្ថិតិជនពិការដែលអាចប្រៀបធៀបគ្នាបានតាមពេលវេលានិងឆ្លងប្រទេស។ វាជាការសំខាន់ណាស់ដែលទិន្នន័យមូលដ្ឋានសម្រាប់សូចនាករយុទ្ធសាស្ត្រអ៊ីនឈាន់ត្រូវបានបង្កើតឲ្យមានដើម្បីធ្វើឲ្យការតាមដានភាពរីកចំរើនមានប្រសិទ្ធភាពឆ្ពោះទៅរកការសម្រេចគោលដៅនិងទិសដៅ។

**ទិសដៅ ៨.ក**

**ផលិតនិងផ្សព្វផ្សាយស្ថិតិជនពិការដែលអាចជឿទុកចិត្តបាន និងអាចប្រៀបធៀបបានជាលក្ខណៈអន្តរជាតិក្នុងទម្រង់ដែលអាចប្រើប្រាស់បានដោយជនពិការ**

**ទិសដៅ ៨.ខ**

**បង្កើតស្ថិតិជនពិការដែលអាចជឿទុកចិត្តបាននៅពាក់កណ្តាលទសវត្សរ៍ (ឆ្នាំ២០១៧) ជាប្រភពសម្រាប់តាមដានភាពរីកចំរើនឆ្ពោះទៅរកការសម្រេចគោលដៅនិងទិសដៅនៃយុទ្ធសាស្ត្រអ៊ីនឈាន់**

### សូចនាករសម្រាប់តាមដានភាពរីកចំរើន

#### សូចនាករស្នូល

៨.១ វិសាលភាពនៃជនពិការដែលផ្អែកលើចំណាត់ថ្នាក់អន្តរជាតិនៃមុខងារពិការភាព និងសុខភាព(ICF) តាមអាយុ ភេទ ជាតិសាសន៍ និងស្ថានភាពសេដ្ឋកិច្ចសង្គម

៨.២ ចំនួនរដ្ឋាភិបាលនៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិកដែលនឹងបង្កើតបាននៅឆ្នាំ២០១៧ នូវទិន្នន័យមូលដ្ឋានសម្រាប់តាមដានភាពរីកចំរើនឆ្ពោះទៅរកការសម្រេចគោលដៅ និងទិសដៅអ៊ីនឈាន់

៨.៣ មានទិន្នន័យផ្សេងពីគ្នាអំពីស្ត្រីនិងក្មេងស្រីពិការនៅក្នុងកម្មវិធីអភិវឌ្ឍន៍និងសេវារដ្ឋាភិបាល ដែលរួមមានដូចជាកម្មវិធីសុខភាព កម្មវិធីសុខភាពផ្លូវភេទនិងបន្តពូជ

# គោលដៅទី ៩

## ពន្លឿនការផ្តល់សច្ចាប័ននិងការអនុវត្តន៍អនុសញ្ញាស្តីពីសិទ្ធិជនពិការនិងការធ្វើសុខដុមនីយកម្មនីតិកម្មជាតិជាមួយអនុសញ្ញានេះ

**១៩.** អនុសញ្ញាស្តីពីសិទ្ធិជនពិការ គឺជាលិខិតុបករណ៍ដែលផ្តោតជាក់លាក់ទៅលើជនពិការនិងស្របតាមច្បាប់អន្តរជាតិទីមួយដែលផ្តល់មធ្យោបាយទូលំទូលាយមួយដល់ការគោរពការការពារនិងការបំពេញសិទ្ធិរបស់ជនពិការ។ អនុសញ្ញានេះលើកកម្ពស់សមត្ថភាពជនពិការយ៉ាងជាក់ច្បាស់ ក្នុងឋានៈជាម្ចាស់សិទ្ធិ និងក្នុងលក្ខណៈផ្សេងពីការដែលត្រូវបានគេចាត់ទុកជាកម្មវត្ថុនៃសប្បុរសធម៌។ តំបន់ អេស្កាប់ បានដើរតួជាឧបករណ៍និងជាប្រវត្តិសាស្ត្រនៅក្នុងការផ្តួចផ្តើមនិងការព្រាងអនុសញ្ញានេះ។ គិតមកត្រឹមថ្ងៃទី ៣០ ខែតុលា ឆ្នាំ២០១២ ក្នុងពិភពលោកមានរដ្ឋចំនួន១២៦ជាភាគីនៃអនុសញ្ញានេះ និងរដ្ឋចំនួន១៥៤ ជារដ្ឋហត្ថលេខី នៅក្នុងចំណោមនោះ រដ្ឋាភិបាលចំនួន៣៥នៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិកបានចុះហត្ថលេខាលើអនុសញ្ញានេះ ហើយមានរដ្ឋាភិបាលចំនួន២៥នៅក្នុងតំបន់នេះបានផ្តល់សច្ចាប័នឬយល់ព្រមអនុវត្តអនុសញ្ញានេះ។

### ទិសដៅ ៩.ក

**នៅពាក់កណ្តាលទសវត្សរ៍ (២០១៧) រដ្ឋាភិបាលក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិកចំនួន១០បន្ថែមទៀត នឹងបានផ្តល់សច្ចាប័នឬយល់ព្រមអនុវត្តអនុសញ្ញាស្តីពីសិទ្ធិជនពិការ ហើយនៅចុងទសវត្សរ៍ (២០២២) រដ្ឋាភិបាលក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកចំនួន១០ផ្សេងទៀតនឹងបានផ្តល់សច្ចាប័ន ឬយល់ព្រមអនុវត្តអនុសញ្ញានេះ**

### ទិសដៅ ៩.ខ

**អនុម័តច្បាប់ជាតិដែលដាក់បញ្ចូលបទប្បញ្ញត្តិប្រឆាំងការរើសអើង បទដ្ឋានបច្ចេកទេស និងវិធានការផ្សេងៗទៀត ដើម្បីជួយគាំពារនិងការពារសិទ្ធិរបស់ជនពិការ និងធ្វើវិសោធនកម្មឬលុបចោលច្បាប់ជាតិណាដែលរើសអើងដោយផ្ទាល់ឬប្រយោលចំពោះជនពិការ ដើម្បីធ្វើសុខដុមនីយកម្មរវាងនីតិកម្មជាតិជាមួយអនុសញ្ញានេះ**

---

## សូចនាករសម្រាប់តាមដានភាពរីកចំរើន

### សូចនាករស្នូល

៩.១ ចំនួនរដ្ឋាភិបាលដែលបានផ្តល់សច្ចាប័នឬយល់ព្រមអនុវត្តអនុសញ្ញានេះ

៩.២ មាននីតិកម្មជាតិដែលប្រឆាំងនឹងការរើសអើង ដើម្បីជួយគាំពារនិងការពារសិទ្ធិរបស់ជនពិការ

### សូចនាករបន្ថែម

៩.៣ ចំនួនរដ្ឋាភិបាលក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិកដែលបានផ្តល់សច្ចាប័នលើពិធីសារបន្ថែមចំពោះអនុសញ្ញាស្តីពីសិទ្ធិជនពិការ

៩.៤ ចំនួនច្បាប់ដែលរើសអើងដោយផ្ទាល់ ឬដោយប្រយោលចំពោះជនពិការដែលត្រូវបានធ្វើវិសោធនកម្មឬលុបចោល

## គោលដៅ ១០
## ពង្រីកកិច្ចសហប្រតិបត្តិការថ្នាក់អនុតំបន់ ថ្នាក់តំបន់ និងថ្នាក់អន្តរតំបន់

២០. បទពិសោធន៍ដែលបានមកពីពីរទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក គូសបញ្ជាក់ពីតម្លៃនៃកិច្ចសហប្រតិបត្តិការនៅថ្នាក់អនុតំបន់ ថ្នាក់តំបន់ និងថ្នាក់អន្តរតំបន់ សម្រាប់សម្រួលការជួយទ្រទ្រង់គ្នាទៅវិញទៅមក ដែលរួមមានទាំងតាមរយៈការចែករំលែកមេរៀនពិសោធន៍ ការអនុវត្តន៍ល្អ និងដំណោះស្រាយក្នុងរបៀបថ្មីៗ។ ភាពជាដៃគូប៊ូសានដើម្បីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព[៩] បានអនុម័តនៅថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១១ ដោយវេទិកាកម្រិតខ្ពស់ស្តីពីប្រសិទ្ធភាពនៃជំនួយលើកទីបួននៅទីក្រុងប៊ូសានសាធារណរដ្ឋកូរ៉េ បានទទួលស្គាល់ពីសារៈសំខាន់នៃការប្តេជ្ញាចិត្តជាអន្តរជាតិស្តីពីពិការភាព ដើម្បីបង្កើតជាមូលដ្ឋានគ្រឹះនៃកិច្ចសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយប្រសិទ្ធភាព។ សង្គមស៊ីវិលនិងផ្នែកឯកជន អាចនឹងដើរតួសំខាន់នៅក្នុងការពន្លឿនវិធីសាស្ត្រថ្មីឆ្ពោះទៅដល់ការសម្រេចគោលដៅនិងទិសដៅអ៊ីនឈាន់។ តំបន់អាស៊ីនិងប៉ាស៊ីហ្វិក នៅប្រឈមមុខនឹងបញ្ហារយៈពេលវែងទៀត។ នៅក្នុងបណ្តាតំបន់ក្រោយជម្លោះ បញ្ហាដូចជាគ្រាប់មីននិងសំណល់ជាតិផ្ទុះសល់ពីសង្គ្រាមនៅកំពុងបន្តបង្កើនពិការភាព និងធ្វើឲ្យអន្តរាយដល់ជីវភាពរស់នៅ។ ជាមួយវិសាលភាព ពហុផ្នែក ទសវត្សរ៍នេះ ផ្តល់ឱកាសមួយសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីដោះស្រាយឲ្យបាននូវបញ្ហាទាំងនេះ និងដើម្បីទ្រទ្រង់ដល់ការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព។

### ទិសដៅ ១០.ក
រួមចំណែកជាមួយពហុម្ចាស់ជំនួយក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិកដែលគ្រប់គ្រងដោយ អេស្កាប់ ព្រមទាំងការផ្តួចផ្តើមនិងកម្មវិធីនានា ដើម្បីគាំទ្រការអនុវត្តន៍សេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីស្តីពីទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ២០១៣-២០២២ និងយុទ្ធសាស្ត្រអ៊ីនឈាន់

### ទិសដៅ ១០.ខ
ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍នៅក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ពង្រឹងការដាក់បញ្ចូលជនពិការទៅក្នុងគោលនយោបាយនិងកម្មវិធីនានារបស់ខ្លួន

### ទិសដៅ ១០.គ
បណ្តាគណៈកម្មាធិការប្រចាំតំបន់នៃអង្គការសហប្រជាជាតិពង្រឹងការផ្លាស់ប្តូរបទពិសោធន៍ និងការអនុវត្តន៍ល្អក្នុងកម្រិតអន្តរតំបន់ដែលទាក់ទងនឹងជនពិការ និងពង្រឹងការអនុវត្តន៍អនុសញ្ញាស្តីពីសិទ្ធិជនពិការ

សូចនាករសម្រាប់តាមដាន ភាពរីកចំរើន

[៩] មើល www.aideffectiveness.org/busanhlf4/images/stories/hlf4/OUTCOME_DOCUMENT_-_FINAL_EN.pdf

១០.១ វិភាគទានស្ម័គ្រចិត្តប្រចាំឆ្នាំពីបណ្ដារដ្ឋាភិបាល និងពីម្ចាស់ជំនួយផ្សេងៗទៀតដែលផ្ដល់ទៅឱ្យ ពហុម្ចាស់ជំនួយក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ដើម្បីទ្រទ្រង់ដល់ការអនុវត្តន៍សេចក្ដីប្រកាសថ្នាក់រដ្ឋមន្ត្រីស្ដីពីទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក២០១៣-២០២២ និងយុទ្ធសាស្ត្រអ៊ីនឈាន់

១០.២ ចំនួនម្ចាស់ជំនួយដែលរួមវិភាគទានជារៀងរាល់ឆ្នាំទៅឱ្យពហុម្ចាស់ជំនួយក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក ដើម្បីទ្រទ្រង់ដល់ការអនុវត្តន៍សេចក្ដីប្រកាសថ្នាក់រដ្ឋមន្ត្រីស្ដីពីទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក២០១៣-២០២២ និងយុទ្ធសាស្ត្រអ៊ីនឈាន់

១០.៣ វិភាគទានស្ម័គ្រចិត្តប្រចាំឆ្នាំពីបណ្ដារដ្ឋាភិបាល និងម្ចាស់ជំនួយផ្សេងៗទៀតសម្រាប់ការផ្ដួចផ្ដើមនិងកម្មវិធីនានា ដើម្បីទ្រទ្រង់ដល់ការអនុវត្តន៍សេចក្ដីប្រកាសថ្នាក់រដ្ឋមន្ត្រីស្ដីពីទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក២០១៣-២០២២ និងយុទ្ធសាស្ត្រអ៊ីនឈាន់

១០.៤ ចំនួនអង្គភាពរបស់អង្គការសហប្រជាជាតិដែលមានកម្មវិធីសហប្រតិបត្តិការថ្នាក់តំបន់ ដែលរួមមានទាំងកិច្ចសហប្រតិបត្តិការត្បូង-ត្បូង ដែលគាំទ្រជាក់លាក់ដល់ការអនុវត្តន៍សេចក្ដីប្រកាសថ្នាក់រដ្ឋមន្ត្រីស្ដីពីទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក២០១៣-២០២២ និងយុទ្ធសាស្ត្រអ៊ីនឈាន់

១០.៥ ចំនួនស្ថាប័នអន្តររដ្ឋាភិបាលថ្នាក់អនុតំបន់ដែលមានកម្មវិធីនានា ដែលរួមទាំងកម្មវិធីសម្រាប់កិច្ចសហប្រតិបត្តិការត្បូង-ត្បូង ដែលគាំទ្រដល់ការអនុវត្តន៍សេចក្ដីប្រកាសថ្នាក់រដ្ឋមន្ត្រីស្ដីពីទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក២០១៣-២០២២ និងយុទ្ធសាស្ត្រអ៊ីនឈាន់

១០.៦ ចំនួនគម្រោងថ្នាក់តំបន់និងអនុតំបន់ដែលរួមទាំងកិច្ចសហប្រតិបត្តិការត្បូង-ត្បូង ដែលក្នុងនោះបណ្ដាអង្គការជនពិការ និងអង្គការសម្រាប់ជនពិការ ចូលរួមដើម្បីគាំទ្រការអនុវត្តន៍សេចក្ដីប្រកាសថ្នាក់រដ្ឋមន្ត្រីស្ដីពីទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក២០១៣-២០២២ និងយុទ្ធសាស្ត្រអ៊ីនឈាន់

១០.៧ ចំនួនទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍ដែលកំពុងប្រតិបត្តិការនៅក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក ដែលមានអាណត្តិ គោលនយោបាយ ផែនការសកម្មភាព ដែលបានខិតខំនិងមានបទពិសោធន៍ល្អលើចំណុចប្រសព្វអំពីការអភិវឌ្ឍន៍ដែលមានដាក់បញ្ចូលជនពិការ ដែលគាំទ្រដល់ការផ្ដល់សច្ចាប័ននិងការអនុវត្តន៍អនុសញ្ញានេះ រួមទាំងការគាំទ្រដល់ការពិនិត្យមើលឡើងវិញនូវសកម្មភាពតាមដាន

១០.៨ ចំនួនសកម្មភាពរួមនៅក្នុងចំណោមគណៈកម្មាធិការតំបន់ទាំងប្រាំរបស់អង្គការសហប្រជាជាតិ ដើម្បីគាំទ្រដល់ការអនុវត្តន៍អនុសញ្ញាស្ដីពីសិទ្ធិជនពិការ

១០.៩ ចំនួនអ្នកជំនាញស្ថិតិនៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិកដែលត្រូវបានបណ្ដុះបណ្ដាលផ្នែកស្ថិតិជនពិការ ជាពិសេសការអនុវត្តន៍ចំណាត់ថ្នាក់អន្តរជាតិនៃមុខងារពិការភាព និងសុខភាព (ICF) ដោយ អេស្កាប់ និងភ្នាក់ងារពាក់ព័ន្ធផ្សេងៗទៀត

១០.១០ ចំនួនក្របខណ្ឌជំនួយអភិវឌ្ឍន៍ថ្នាក់ប្រទេស ឬតំបន់ របស់អង្គការសហប្រជាជាតិដែលបញ្ជាក់ច្បាស់លាស់ពីការអភិវឌ្ឍន៍ដែលមានរួមបញ្ចូលពិការភាព ដែលស្របទៅតាមសេចក្ដីណែនាំរបស់ក្រុមអភិវឌ្ឍន៍អង្គការសហប្រជាជាតិស្ដីពីការរួមបញ្ចូលសិទ្ធិរបស់ជនពិការទៅក្នុងកម្មវិធីអង្គការសហប្រជាជាតិក្នុងកម្រិតប្រទេស

## ឃ. គម្រូសម្រាប់ការអនុវត្តន៍ប្រកបដោយប្រសិទ្ធភាព៖ ថ្នាក់ជាតិ ថ្នាក់អនុតំបន់ និង ថ្នាក់តំបន់

**២១.** ផ្នែកនេះកំណត់នូវគម្រូដែលលើកកម្ពស់និងគាំទ្រការអនុវត្តន៍។ ជាពិសេសគម្រូទាំងនេះកសាងទិន្នន័យនិងព័ត៌មាន និងពង្រឹងកិច្ចសហប្រតិបត្តិការពហុកម្រិតសម្រាប់ជំរុញភាពរីកចំរើនទៅរកការសម្រេចឲ្យបាននូវសិទ្ធិរបស់ជនពិការ តាមរយៈការអនុវត្តន៍យុទ្ធសាស្ត្រអ៊ីនឈាន់នៅក្នុងរយៈពេលនៃទសវត្សរ៍នេះ។

---

### ១. ថ្នាក់ជាតិ

**២២.** ចំណុចសំខាន់នៃការអនុវត្តយុទ្ធសាស្ត្រអ៊ីនឈាន់ គឺជាយន្តការសម្របសម្រួលថ្នាក់ជាតិស្ដីអំពីពិការភាពជាមួយនឹងទំនាក់ទំនងថ្នាក់ក្រោមជាតិសំខាន់ៗទាំងអស់របស់វា។

**២៣.** យន្តការជាច្រើនក្នុងចំណោមយន្តការទាំងនេះ ត្រូវបានបង្កើតនៅក្នុងរយៈពេលពីរទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិកកន្លងទៅនេះ។ ដូច្នេះយន្តការទាំងនោះនឹងរ៉ាប់រងការទទួលខុសត្រូវចម្បងក្នុងការសម្របសម្រួល និងពន្លឿនការអនុវត្តន៍យុទ្ធសាស្ត្រអ៊ីនឈាន់នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

**២៤.** នៅក្រោមការទំនុកបម្រុងរបស់យន្តការសម្របសម្រួលជាតិ ការិយាល័យស្ថិតិជាតិនឹងទទួលតួនាទីជាចំណុចប្រសព្វក្នុងការបង្កើតទិន្នន័យមូលដ្ឋានសម្រាប់សូចនាករ និងតាមដានភាពរីកចំរើននៅក្នុងការអនុវត្តន៍យុទ្ធសាស្ត្រអ៊ីនឈាន់។

**២៥.** យន្តការសម្របសម្រួលជាតិស្ដីអំពីពិការភាព គួរមានភារៈកិច្ចដូចខាងក្រោម ប៉ុន្តែមិនមានកំណត់៖

ក. ធ្វើចលនាបណ្ដាក្រសួង ផ្នែក នាយកដ្ឋាន និងស្ថាប័នរដ្ឋាភិបាលគ្រប់ជាន់ថ្នាក់ សង្គមស៊ីវិល ដែលរួមមានទាំងបណ្ដាអង្គការជនពិការនិងអង្គការសម្រាប់ជនពិការនិងក្រុមទ្រទ្រង់គ្រួសាររបស់ពួកគេស្ថាប័នស្រាវជ្រាវ និងផ្នែកឯកជន សម្រាប់ការចូលរួមនៅក្នុងការអនុវត្តន៍យុទ្ធសាស្ត្រអ៊ីនឈាន់ជាលក្ខណៈពហុផ្នែកនិងក្នុងកម្រិតជាតិ

ខ. អភិវឌ្ឍពិនិត្យតាមដាននិងធ្វើរបាយការណ៍អំពីការអនុវត្តន៍ផែនការសកម្មភាពជាតិស្ដីពីការសម្រេចឲ្យបាននូវគោលដៅនិងទិសដៅរបស់យុទ្ធសាស្ត្រអ៊ីនឈាន់

គ. បកប្រែយុទ្ធសាស្ត្រអ៊ីនឈាន់ជាភាសាជាតិនិងធានាភាពមាននៃសំណៅជាភាសាជាតិក្នុងទម្រង់ដែលអាចប្រើប្រាស់បានសម្រាប់ការផ្សព្វផ្សាយដែលមានលក្ខណៈទូលំទូលាយទៅកាន់គ្រប់ផ្នែក និងគ្រប់ថ្នាក់រដ្ឋបាល

ឃ. ទទួលរ៉ាប់រងលើការឃោសនាថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដូចជាយុទ្ធនាការឃោសនា**ធ្វើឲ្យសិទ្ធិក្លាយជាការពិត**! ដើម្បីលើកកម្ពស់ការយល់ដឹងនៅក្នុងកំឡុងពេលនៃទសវត្សរ៍ដែលលើកតម្កើងទស្សនៈវិជ្ជមានរបស់ជនពិការ

ង. លើកកម្ពស់និងគាំទ្រការស្រាវជ្រាវអំពីស្ថានភាពរបស់ជនពិការ ដើម្បីជាមូលដ្ឋានមួយសម្រាប់ការកសាងគោលនយោបាយ។

២៦. ក្រុមអង្គការសហប្រជាជាតិប្រចាំប្រទេសគួរគាំទ្រការធ្វើឲ្យមានសកម្មភាពឡើងវិញនិងការប្រព្រឹត្តទៅនៃយន្តការសម្របសម្រួលថ្នាក់ជាតិតាមដែលអាចតម្រូវឲ្យមាន ជាមួយនឹងការយកចិត្តទុកដាក់ពិសេសទៅលើការតស៊ូមតិការសម្របសម្រួល និងកិច្ចសហប្រតិបត្តិការដែលនាំទៅរកការអនុវត្តន៍ រួមមានទាំងនៅថ្នាក់ក្រោមជាតិ។

## ២. ថ្នាក់អនុតំបន់

២៧. អង្គភាពអន្តររដ្ឋាភិបាលថ្នាក់អនុតំបន់ មានដូចជាសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ អង្គការសហប្រតិបត្តិការសេដ្ឋកិច្ច វេទិកាកោះប៉ាស៊ីហ្វិក និងសមាគមអាស៊ីខាងត្បូងសម្រាប់កិច្ចសហប្រតិបត្តិការក្នុងតំបន់ជាដើម មានតួនាទីយ៉ាងសំខាន់នៅក្នុងការរួមចំណែកពន្លឿនការអនុវត្តន៍សេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រី និងយុទ្ធសាស្ត្រអ៊ីនឈាន់ តាមរយៈការផ្សព្វផ្សាយយ៉ាងសកម្មនូវគោលនយោបាយនិងកម្មវិធីដែលមានបញ្ចូលជនពិការនៅក្នុងអាណត្តិរៀងខ្លួនរបស់ពួកគេ។

២៨. លេខាធិការដ្ឋាន អេស្កាប់ នៅក្នុងការផ្សព្វផ្សាយទសវត្សរ៍ជនពិការអាស៊ីនិងប៉ាស៊ីហ្វិក២០១៣-២០២២ របស់ខ្លួនត្រូវគាំទ្រកិច្ចសហប្រតិបត្តិការថ្នាក់អនុតំបន់ និងអន្តរអនុតំបន់ក្នុងភាពជាដៃគូជាមួយបណ្តាស្ថាប័នអន្តររដ្ឋាភិបាលថ្នាក់អនុតំបន់។ ដូច្នេះ លេខាធិការដ្ឋានត្រូវគ្រប់គ្រងការចូលរួមយ៉ាងសកម្មនៃបណ្តាការិយាល័យថ្នាក់អនុតំបន់របស់ខ្លួននៅក្នុងតំបន់អាស៊ីខាងជើងនិងអាស៊ីកណ្តាល អាស៊ីខាងកើតនិងអគ្នេយ៍ តំបន់ប៉ាស៊ីហ្វិក និងអាស៊ីខាងត្បូងនិងអាស៊ីប៉ែកនិរតី ដែលគាំទ្រដោយស្ថាប័នថ្នាក់តំបន់របស់ខ្លួន[៥] នៅក្នុងការលើកកម្ពស់ការអភិវឌ្ឍន៍ដែលមានដាក់បញ្ចូលពិការភាព។

## ៣. ថ្នាក់តំបន់

២៩. សមាជិកនិងសមាជិកធម្មតារបស់ អេស្កាប់ គួរពិភាក្សាអំពីភាពរីកចំរើននិងទម្លាប់អនុវត្តន៍ល្អនៅក្នុងការអនុវត្តន៍សេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីនិងយុទ្ធសាស្ត្រអ៊ីនឈាន់ នៅក្នុងកិច្ចប្រជុំជាប្រចាំនៃគណៈកម្មាធិការអភិវឌ្ឍន៍សង្គម ឬស្ថាប័នដែលមានតម្លៃស្មើរបស់ខ្លួន។ បណ្តាតំណាងនៃអង្គការសង្គមស៊ីវិលត្រូវបានលើកទឹកចិត្តឲ្យចូលរួមក្នុងកិច្ចប្រជុំទាំងនោះ។

៣០. ត្រូវបង្កើតឲ្យមានក្រុមការងារប្រចាំតំបន់មួយសម្រាប់ការងារទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក២០១៣ ២០២២។ ក្រុមការងារនេះ ត្រូវគាំទ្រការអនុវត្តន៍ពេញលេញនិងមានប្រសិទ្ធភាពនៅពេញកំឡុងពេលនៃទសវត្សរ៍។ មុខងាររបស់ក្រុមការងារនេះ ត្រូវផ្តោតលើការពិគ្រោះយោបល់និងការគាំទ្រចំពោះការអនុវត្តន៍សេចក្តីប្រកាស

[៥] មជ្ឈមណ្ឌលបណ្តុះបណ្តាលអាស៊ីនិងប៉ាស៊ីហ្វិកសម្រាប់បច្ចេកវិទ្យាព័ត៌មាននិងទំនាក់ទំនងសម្រាប់ការអភិវឌ្ឍន៍(APCICT)អ៊ីនឈាន់ សាធារណរដ្ឋកូរ៉េ; មជ្ឈមណ្ឌលអាស៊ីនិងប៉ាស៊ីហ្វិកសម្រាប់ការផ្ទេរបច្ចេកវិទ្យា(APCTT) ញូវដេលី; វិទ្យាស្ថានស្ថិតិសម្រាប់តំបន់អាស៊ីនិងប៉ាស៊ីហ្វិក(SIAP)តូក្យូ;

ថ្នាក់រដ្ឋមន្ត្រីនិងយុទ្ធសាស្ត្រអ៊ីនឈាន់ដល់សមាជិកនិងសមាជិកធម្មតាទៅតាមភាពសមស្រប។ សេចក្តីព្រាងលក្ខខណ្ឌយោងរបស់ក្រុមការងារនេះ ត្រូវបានភ្ជាប់ជាឧបសម្ព័ន្ធ។

៣១. លេខាធិការដ្ឋាន អេស្កាប់ ត្រូវរួមចំណែកនៅក្នុងការអនុវត្តន៍សេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីនិងយុទ្ធសាស្ត្រអ៊ីនឈាន់តាមរយៈតួនាទី កោះប្រជុំក្នុងតំបន់ធ្វើការវិភាគ និងទ្រទ្រង់បច្ចេកទេសរបស់ខ្លួនចំពោះរដ្ឋាភិបាល។ ជាពិសេសលេខាធិការដ្ឋានត្រូវទទួលរ៉ាប់រងធ្វើកិច្ចការខាងក្រោមនេះ នៅក្នុងកិច្ចសហប្រតិបត្តិការជាមួយបណ្តាអង្គភាពរបស់អង្គការសហប្រជាជាតិ៖

ក. គាំទ្ររដ្ឋាភិបាលទៅតាមភាពសមស្របនៅក្នុងការធ្វើសុខដុមនីយកម្មនីតិកម្មជាមួយអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងលើកកម្ពស់ការធ្វើយុទ្ធនាការឃោសនា **"ធ្វើឲ្យសិទ្ធិក្លាយជាការពិត!"**

ខ. លើកកម្ពស់ការចែករំលែកក្នុងចំណោមសមាជិកនិងសមាជិកធម្មតា នូវបទពិសោធន៍និងទម្លាប់អនុវត្តន៍ល្អរបស់ថ្នាក់ជាតិក្នុងការអភិវឌ្ឍន៍ដែលមានការដាក់បញ្ចូលពិការភាព និងក្នុងការការពារនិងគាំពារសិទ្ធិរបស់ជនពិការ ដែលរួមមានទាំងការចែករំលែកបទពិសោធន៍ក្នុងចំណោមស្ថាប័ននីតិកម្ម ឬរដ្ឋបាលជាតិ ដើម្បីលើកកម្ពស់និងគាំទ្រអនុសញ្ញាស្តីពីសិទ្ធិជនពិការ

គ. តាមដានភាពរីកចំរើន និងគាំទ្រការធ្វើអោយប្រសើរឡើងនូវស្ថិតិស្តីពីពិការភាពក្នុងកំឡុងពេលនៃទសវត្សរ៍

ឃ. គាំទ្រសមាជិកនិងសមាជិកធម្មតាក្នុងការកសាងសមត្ថភាព ដើម្បីលើកកម្ពស់ការអភិវឌ្ឍន៍ដែលមានបញ្ចូលពិការភាព

ង. ចូលរួមជាមួយបណ្តាអង្គការសង្គមស៊ីវិល ជាពិសេសអង្គការជនពិការ និងអង្គការសម្រាប់ជនពិការ និងផ្តល់វេទិកាថ្នាក់តំបន់មួយសម្រាប់ការពិគ្រោះយោបល់ពីភាគីពាក់ព័ន្ធ

៣២. មជ្ឈមណ្ឌលអភិវឌ្ឍន៍ជនពិការប្រចាំតំបន់អាស៊ី-ប៉ាស៊ីហ្វិក ត្រូវបានបង្កើតជាមរតកដំបូងមួយនៃទសវត្សរ៍ជនពិការអាស៊ីនិងប៉ាស៊ីហ្វិក ដើម្បីលើកកម្ពស់សមត្ថភាពរបស់ជនពិការ និងអង្គការតំណាងរបស់ពួកគេ និងលើកកម្ពស់សង្គមមួយដែលគ្មានឧបសគ្គរាំងនិងដែលដាក់បញ្ចូលពិការភាព ត្រូវបានសុំឲ្យបន្តកសាងសមត្ថភាពរបស់ជនពិការនិងកិច្ចសហការពហុផ្នែកជាមួយនឹងការយកចិត្តទុកដាក់ពិសេសលើការលើកទឹកចិត្តឲ្យមានការចូលរួមរបស់ផ្នែកឯកជននៅក្នុងធុរកិច្ចដែលមានដាក់បញ្ចូលពិការភាព និងធុរកិច្ចដែលលើកកម្ពស់ការផ្សព្វផ្សាយផលិតផល សេវា ឱកាសការងារ និងការអភិវឌ្ឍន៍សហគ្រិនភាពដែលត្រូវគ្នានឹងជនពិការ។

៣៣. មូលនិធិធ្វើឲ្យសិទ្ធិក្លាយជាការពិត ដែលបានផ្តួចផ្តើមដោយនិងមានមូលដ្ឋាននៅក្នុងសាធារណរដ្ឋកូរ៉េ ត្រូវបានស្នើសុំឲ្យគាំទ្រដល់ការអនុវត្តន៍ប្រកបដោយជោគជ័យនៃសេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីអំពីទសវត្សរ៍ជនពិការអាស៊ីនិងប៉ាស៊ីហ្វិក ២០១៣-២០២២ និងយុទ្ធសាស្ត្រអ៊ីនឈាន់។

៣៤. បណ្តាអង្គការសង្គមស៊ីវិលនិងជាពិសេសបណ្តាអង្គការជនពិការនិងអង្គការសម្រាប់ជនពិការ ត្រូវបានលើកទឹកចិត្តឲ្យចូលរួមក្នុងការអនុវត្តន៍សេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីនិងយុទ្ធសាស្ត្រអ៊ីនឈាន់និងលើកកម្ពស់ការឆ្លើយតបជាបន្តបន្ទាប់ចំពោះសេចក្តីប្រាថ្នានិងសេចក្តីត្រូវការរបស់ជនពិការ នៅក្នុងកំឡុងពេលនៃទសវត្សរ៍។

## ឧបសម្ព័ន្ធ
## លក្ខខណ្ឌប្រតិបត្តិរបស់ក្រុមការងារស្តីពីទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក

### គោលបំណង

**១.** គោលបំណងរបស់ក្រុមការងារទសវត្សរ៍ជនពិការអាស៊ីនិងប៉ាស៊ីហ្វិកថ្នាក់តំបន់ដែលស្នើឡើងនេះគឺដើម្បីផ្តល់ការពិគ្រោះយោបល់ជំនាញនិងគាំទ្រដល់បណ្តាសមាជិកនិងសមាជិកធម្មតា សំដៅលើកកម្ពស់ការអនុវត្តន៍ពេញលេញនិងមានប្រសិទ្ធភាពនៃទសវត្សរ៍ ២០១៣-២០២២។

### មុខងារ

**២.** អនុលោមទៅតាមគោលដៅដែលចែងនៅក្នុងកថាខណ្ឌ១ខាងលើនេះ ក្រុមការងារត្រូវផ្តល់ការពិគ្រោះយោបល់ដល់បណ្តាសមាជិកនិងសមាជិកធម្មតា នូវចំណុចដូចខាងក្រោម៖

ក. ការពិនិត្យមើលឡើងវិញនូវភាពរីកចំរើននៃទសវត្សរ៍ ជាពិសេសដែលទាក់ទងនឹងការអនុវត្តន៍សេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីអំពីទសវត្សរ៍ជនពិការប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក២០១៣-២០២២ និងយុទ្ធសាស្ត្រអ៊ីនឈាន់"**ធ្វើឲ្យសិទ្ធិក្លាយជាការពិត**"សម្រាប់ជនពិការនៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក

ខ. សហប្រតិបត្តិការថ្នាក់តំបន់និងអនុតំបន់ ដើម្បីជំរុញការអនុវត្តន៍សេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រី និងយុទ្ធសាស្ត្រអ៊ីនឈាន់

គ. សិក្សាស្រាវជ្រាវអំពីស្ថានភាពវិវត្តន៍នៃជនពិការ នៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក

ឃ. ចុះទៅដល់ក្រុមជនពិការប្រភេទផ្សេងៗក្នុងកម្រិតជាតិនិងមូលដ្ឋាន និងរៀបចំជាបណ្តាញ។

### សមាជិកភាព

**៣.** ក្រុមការងារនេះ ត្រូវមានសមាសភាពរួមផ្សំឡើងដោយតំណាងនៃសមាជិកនិងសមាជិកធម្មតារបស់ អេស្កាប់ និងបណ្តាអង្គការសង្គមស៊ីវិលដែលធ្វើប្រតិបត្តិការនៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក នៅកម្រិតតំបន់និងអនុតំបន់។

**៤.** រយៈពេលកាន់មុខតំណែងរបស់សមាជិកនៃក្រុមការងារនេះត្រូវមានរយៈពេលប្រាំឆ្នាំ នឹងមានលទ្ធភាពបន្តសម្រាប់រយៈពេលប្រាំឆ្នាំម្តងទៀត។

**៥.** សមាជិកនិងសមាជិកធម្មតារបស់ អេស្កាប់ ទាំងអស់មានសិទ្ធិត្រូវបានជ្រើសរើសឲ្យបម្រើការនៅក្នុងក្រុមការងារនេះ។

**៦.** ក្រុមការងារនេះគួរត្រូវបានផ្សំឡើងដោយសមាជិកចំនួន៣០រូប ដោយគិតពីសមភាពយេនឌ័រ៖ ១៥រូបពីសមាជិកនិងសមាជិកធម្មតា និង១៥រូបពីអង្គការសង្គមស៊ីវិល។ យ៉ាងហោចណាស់ចំនួនអាសនៈពាក់កណ្តាលនៃអាសនៈដែលត្រូវបានបម្រុងសម្រាប់អង្គការសង្គមស៊ីវិលគួរត្រូវបានធានាសម្រាប់ជនពិការនិងអង្គការសង្គមស៊ីវិលដែលទើបត្រូវបានបញ្ចូលជាសមាជិក។

**៧.** អង្គភាពសង្គមស៊ីវិលដែលត្រូវនឹងលក្ខណៈវិនិច្ឆ័យខាងក្រោមត្រូវមានសិទ្ធិជ្រើសរើសឲ្យបម្រើការជាសមាជិកនៃក្រុមការងារនេះផងដែរ៖ (ក). ប្រតិបត្តិការក្នុងកម្រិតតំបន់និង/ឬអនុតំបន់នៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក (ខ). គឺជាអង្គការឬបណ្តាញដែលតំណាង គាំទ្រ និង/ឬលើកកម្ពស់ផលប្រយោជន៍របស់ជនពិការ (គ). មានជំនាញបច្ចេកទេសពាក់ព័ន្ធនឹងការជំរុញនូវការអនុវត្តន៍សេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រីនិងយុទ្ធសាស្ត្រអ៊ីនឈាន់។

៨. ការប្រកាសពីចំណាប់អារម្មណ៍ដោយសមាជិកនិងសមាជិកធម្មតារបស់ អេស្កាប់ និងអង្គការសង្គមស៊ីវិល នៅក្នុងការបម្រើជាសមាជិកនៃក្រុមការងារនេះ គួរធ្វើនៅក្នុងកិច្ចប្រជុំអន្តររដ្ឋាភិបាលកម្រិតខ្ពស់ស្តីពីការពិនិត្យមើលឡើងវិញចុងក្រោយនៃការអនុវត្តន៍នៃទសវត្សរ៍ជនពិការអាស៊ីនិងប៉ាស៊ីហ្វិក២០១៣-២០២២ ដែលនឹងត្រូវប្រព្រឹត្តទៅនៅទីក្រុងអ៊ីនឈាន់ សាធារណរដ្ឋកូរ៉េ ពីថ្ងៃទី២៩ ខែតុលា ដល់ថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០១២។

៩. សមាសភាពក្រុមការងារដែលស្នើឡើងនេះ ត្រូវដាក់ជូនទៅគណៈកម្មាធិការនៅក្នុងសម័យប្រជុំដែលរៀបចំភ្លាមៗបន្ទាប់ពីកិច្ចប្រជុំអន្តររដ្ឋាភិបាលកម្រិតខ្ពស់ ដើម្បីធ្វើការសម្រេចជាចុងក្រោយ។ ដូច្នេះ នៅក្នុងសម័យប្រជុំលើកទីហុកសិបប្រាំបួនរបស់ខ្លួន នៅក្នុងឆ្នាំ២០១៣ គណៈកម្មាធិការនឹងធ្វើការសម្រេចជាចុងក្រោយលើសមាសភាពនៃក្រុមការងារសម្រាប់រយៈពេលទីមួយ គឺរយៈពេល២០១៣-២០១៧។ ការប្រកាសលើកទីពីរនៃចំណាប់អារម្មណ៍ក្នុងការបម្រើការនៅក្នុងក្រុមការងារនេះ ត្រូវធ្វើនៅក្នុងកិច្ចប្រជុំអន្តររដ្ឋាភិបាលកម្រិតខ្ពស់ ដែលនឹងត្រូវបានកោះប្រជុំនៅពាក់កណ្តាលទសវត្សរ៍ (២០១៧)។ នៅក្នុងសម័យប្រជុំលើកទី ចិតសិបបួនរបស់ខ្លួននៅក្នុងឆ្នាំ២០១៨ គណៈកម្មាធិការនឹងធ្វើការសម្រេចជាចុងក្រោយលើសមាសភាពនៃក្រុមការងារសម្រាប់លើកទីពីរ គឺរយៈពេល២០១៨-២០២២។

១០. បណ្តាសមាជិកនិងសមាជិកធម្មតារបស់ អេស្កាប់ អង្គការសង្គមស៊ីវិលជាពិសេសអង្គការជនពិការទីភ្នាក់ងារអនុតំបន់និងអន្តររដ្ឋាភិបាល ទីភ្នាក់ងារអង្គការសហប្រជាជាតិ ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍ និងធនាគារអភិវឌ្ឍន៍ អាចចូលរួមក្នុងកិច្ចប្រជុំនានារបស់ក្រុមការងារនេះ ក្នុងឋានៈជាអ្នកសង្កេតការណ៍។

## វិធាននៃនីតិវិធី

១១. ក្រុមការងារនេះ ត្រូវអនុម័តវិធាននៃនីតិវិធីរបស់ខ្លួន។

## លេខាធិការដ្ឋាន

១២. លេខាធិការដ្ឋាន អេស្កាប់ ត្រូវបម្រើជាលេខាធិការដ្ឋានរបស់ក្រុមការងារនេះ។ លេខាធិការដ្ឋានត្រូវផ្សព្វផ្សាយឯកសាររបស់ក្រុមការងារនៅក្នុងទម្រង់ដែលអាចប្រើប្រាស់បាន។

# ដើម្បីឲ្យជនពិការត្រូវបានគេ៖

មើលឃើញ

ស្តាប់ឮ

រាប់បញ្ចូល

## ចូលរួមគាំទ្រយុទ្ធសាស្ត្រអ៊ីនឈាន់ "ធ្វើឱ្យសិទ្ធិក្លាយជាការពិត" សម្រាប់ជនពិការប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក!










តំបន់ដែលមានពណ៌ដិត គឺជាតំបន់សមាជិកនិងសមាជិកធម្មតារបស់ អេស្កាប់ ។

សម្រាប់ព័ត៌មានបន្ថែមអំពីការងាររបស់ អេស្កាប់ ទាក់ទងនឹងជនពិការ សូមទាក់ទង៖


**នាយក**
ផ្នែកអភិវឌ្ឍន៍សង្គម
គណៈកម្មាធិការសេដ្ឋកិច្ចនិងសង្គមប្រចាំតំបន់អាស៊ីនិងប៉ាស៊ីហ្វិក(ESCAP)
អគារអង្គការសហប្រជាជាតិ
មហាវិថី រាចាដាំនឿនណុក (Rajadamnern Nok)
បាងកក ១០២០០, ប្រទេសថៃ
ទូរស័ព្ទ: (៦៦-២) ២៨៨-១៥១៣  ទូរសារ: (៦៦-២) ២៨៨-១០៣០, (៦៦-២) ២៨៨-៣០៣១
អ៊ីមែល: escap-sdd@un.org